# ជីវិតគឺជាធម្មៈ



រៀបរៀងដោយ

បញ្ញានន្ទោ សុខ គឹមសាន្ត

Dhamma Study and Support Foundation

# ជីវិតគឺជាធម្មៈ



លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាអ្នកមានមេត្តាចិត្តអនុគ្រោះប្រយោជន៍ដល់អ្នកដទៃ ជាសប្បុរសដ៏ឧត្តមសម្តែងព្រះធម៌ដោយសម្លេងពិរោះប្រកបដោយអត្ថន័យខ្លឹមសារលោកគ្រូជាពហុសូត្រអ្នកឆ្លៀវឆ្លាសបកស្រាយពន្យល់ក្នុងគម្ពីរព្រះត្រៃបិដក សិស្សៗគោរពស្រលាញ់លោកគ្រូ អ្នកខ្លះជាប់និងសម្លេងអ្នកខ្លះទៀតជាប់អត្ថរសព្រះធម៌ លោកគ្រូជាឧបាសកគំរូ ជាអ្នកមានចរិយាបរិសុទ្ធ ។

សូមជូនមហាកុសលលោកគ្រូសូមលោកគ្រូមានសុខភាពល្អជន្មាយុយឺនយូរស្ថិតនៅជាម្លប់ដល់សិស្សានុសិស្សក្នុងនិងក្រៅប្រទេស ។

# ពាក្យប្រារព្ធ

សូមពុទ្ធបរិស័ទរីករាយជ្រះថ្លាសិក្សាព្រះធម៌ កូនសៀវភៅ **ជីវិតគឺជាធម្មៈ** ជាធម្មទស្សនៈដែលខ្ញុំព្រះករុណាអាត្មាភាពលើកយកខ្លឹមសារខ្លីៗដែលមានអត្ថន័យរំលឹកដាស់តឿនស្មារតីកុំឲ្យវង្វេងប្រមាទក្នុងជីវិត ជាទស្សនៈឆ្លុះបញ្ចាំងការពិតនៃជីវិតគឺជាធម្មៈគឺការឃើញ ការឮ ការដឹងក្លិន ការដឹងរស ដឹងក្តៅ ដឹងត្រជាក់ រឹង តឹង ទន់ កម្រើក ញ័រ កុសល អកុសល វិបាក ដែលកើតឡើងហើយក៏រលត់ទៅ ជីវិតនេះគ្រាន់តែជា ចិត្ត ចេតសិក រូប ស្តាប់សិក្សាព្រះធម៌ យល់ការពិត បានចាក់ធ្លុះយល់ដឹងសច្ចៈធម៌រមែងអស់នូវការភ័យខ្លាច ការតក់ស្លុត ញាប់ញ័រ ភ័យខ្លាចរឿងចាស់ ភ័យខ្លាចរឿងឈឺ ភ័យខ្លាចរឿងក្រ រឿងព្រាត់ប្រាស់ រឿងអត់លាភ

រឿងអត់យស ជាដើម កាលបើសិក្សាសង្កេត ពិនិត្យការពិតជីវិតដែលជាធម្មៈបានដល់ចិត្ត ចេតសិក រូប ក៏ប្រាកដលក្ខណៈហើយការភ័យខ្លាចតក់ស្លុតញាប់ញ័ររមែងមិនមានឡើយ សូមព្រះគុណម្ចាស់ញាតិញោមកុំធុញទ្រាន់ក្នុងការសិក្សាព្រះអភិធម្ម ព្រះអភិធម្មមិនមែននៅក្នុងគម្ពីរក្បួនច្បាប់នោះទេ គឺនៅក្នុងជីវិតប្រចាំថ្ងៃនេះឯង ខណៈកំពុងឮ កំពុងឃើញជាដើមដោយបរមត្ថជាអភិធម្មគឺមិនមាន ការសេពសោយអារម្មណ៍នៅក្នុងលោកក្រៅពីវេទនានោះមិនមានទេ ការសិក្សាព្រះអភិធម្មគឺការសិក្សាមេរៀនជីវិតស្គាល់ជីវិតខ្លួនឯងបានដល់អ្វី បញ្ញាយល់ពីលក្ខណៈពីធម៌ពិតហើយ រមែងមិនប្រកាន់ហួងហែងអស់នូវទុក្ខផុតកង្វល់ទាំងពួង ផ្លូវនៃការអស់ទុក្ខអស់កង្វល់មានតែមួយគត់ គឺសិក្សាឲ្យស្គាល់ថាជីវិតនេះគឺជាធម្មៈ ធាតុដឹងកើតឡើងហើយក៏ឃើញកើតឡើងហើយក៏នឹកគិត កើតឡើងហើយក៏ចាំ កើតឡើងហើយក៏ដឹង ទាំង

អស់ជាធម្មៈមិនសិក្សាសង្កេតពិនិត្យតួសភាវៈលក្ខណៈដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក អណ្ដាត កាយ ចិត្ត បញ្ញាដែលដឹងការពិតដែលជារូបធម៌នឹងនាមធម៌ ដែលយើងគ្រប់គ្នាប្រកាន់ថារូបសម្លេង ក្លិន រស ផោដ្ឋព្វ ជាយើង តែព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា **សព្វេ ធម្មា អនត្តា** ធម៌ទាំងឡាយជាអនត្តា កាលបើសត្វលោកនៅមិនទាន់ឃើញការពិតនៃជីវិតជាធម្មៈសត្វលោករមែងលង់លក់ក្នុងអវិជ្ជាតណ្ហា អវិជ្ជាបិតផ្លូវព្រះនិព្វានបើកផ្លូវភពបី តណ្ហានាំដើរផ្លូវឆ្ងាយគឺវដ្ដសង្សារ ។

សូមឧទ្ទិសធម្មទាននេះដល់សព្វសត្វ ទេវតាមនុស្ស អមនុស្ស សូមមានចិត្តជ្រះថ្លាក្នុងព្រះរតនត្រៃបានរួចអំពីហីនភាព ភាពថោកទាប រួចពីកោសជ្ជៈ រួចពីការមិនមានសតិរួចពីការមិនខ្មាស់បាបមិនខ្លាចបាប បានជាពុទ្ធបរិស័ទល្អមានព្យាយាមមានទឹកចិត្តដើម្បីទ្រទ្រង់នូវព្រះពុទ្ធសាសនា

ប្ដេជ្ញាបូជាជីវិតដើម្បីសេចក្ដីល្អ ហើយនឹងថែរក្សាព្រះពុទ្ធសាសនាបានពិចារណាឃើញថាក្នុងលោកនេះមិនមានអ្វីជាទីពឹង ដូចជាព្រះរតនត្រៃទេមានតែព្រះរតនត្រៃដែលនាំឲ្យយើងឃើញសច្ចះធម៌ឃើញថាជីវិតនេះគឺជាធម្មះ ឆ្លងរួចផុតអំពីសេចក្ដីទុក្ខ ឆ្លងផុតអន្លង់ឱឃះ អស់នូវបញ្ហាទាំងពួង ក្នុងវដ្ដសង្សារមានព្រះរតនត្រៃជាពន្លឺរស្មី មានចិត្តសណ្ដាន មានអធ្យាស្រ័យប្រណិតឡើង និងខ្ពស់ឡើង រហូតដល់បានរួចផុតអំពីបញ្ចវរាទាំងពួងរួចផុតអំពីអបាយភូមិចូលទៅកាន់ភូមិព្រះអរិយគ្រប់ព្រះអង្គគ្រប់គ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអនុមោទនាបុណ្យ ! សូមអនុមោទនាមហាកុសល !**

**សូមអនុមោទនាមគ្គផល ! សូមឱ្យបានដល់ទីរំលត់ទុក្ខគឺព្រះនិព្វាន កុំបីខានឡើយ! សាធុ សាធុ សាធុ !!!**

**Bangkok ថ្ងៃពុធ ១៥កើត ខែអស្សុជ ព.ស ២៥៥៥**

**ខ្ញុំព្រះករុណាអាត្មាភាព បញ្ញានន្ទោ សុខ គឹមសាន្ដ**

## ១. *អវិជ្ជា*

អវិជ្ជាគឺការមិនដឹងអ្វី? មិនដឹងថាខណៈនេះកំពុងឃើញ កំពុងឮ កំពុងដឹងក្លិន កំពុងដឹងរស កំពុងនឹកគិត មិនទៀងជាទុក្ខមិនមែនយើង ។

## ២. *ជីវិតគឺខណៈដែលកើតឡើង*

ជីវិតគឺខណៈចិត្តដែលកើតឡើង ជីវិតគឺខណៈដែលកើតឡើងតាមផ្លូវភ្នែក ឃើញរូប តាមផ្លូវត្រចៀកឮសម្លេង តាមផ្លូវច្រមុះ ដឹងក្លិន តាមផ្លូវអណ្តាតដឹងរស តាមផ្លូវកាយដឹងក្តៅ ដឹងត្រជាក់ រឹង ទន់ កម្រើក ញ័រ ផ្លូវចិត្តនឹកគិត ជាប់តគ្នាទៅតាមហេតុបច្ច័យតាំងពីកើតរហូតដល់ស្លាប់ ។

## ៣. *ស្តាប់ព្រះធម៌ចិត្តរមែងថ្លាស្អាត*

ពេលដែលមិនបានស្តាប់ព្រះធម៌ ពេលនោះឈ្មោះថា បើកឱកាសឲ្យអកុសលកើត ។

## ៤. *ទ្រព្យពិត*

កុសលគ្រប់ប្រការជាទ្រព្យពិត ចោរលួចមិនបាននឹង បានជាទីពឹងនៃជីវិតយ៉ាងពិតប្រាកដ ។

## ៥. *បុព្វការី*

អ្នកសម្តែងព្រះធម៌ឈ្មោះថាបុព្វការី អ្នកបដិបត្តិធម៌ឈ្មោះថាកតវេទី ព្រះអរហន្តសម្មាសម្ពុទ្ធឈ្មោះថាបុព្វការីរបស់មនុស្សក្នុងលោកព្រមទាំងទេវលោក មារលោកព្រហ្មលោក ព្រះអរិយសាវកឈ្មោះថាកតវេទី ។

## ៦. *ជីវិតចែកចេញជាពីរផ្នែក*

ជីវិតបែងចែកជា ២ ផ្នែក គឺមួយផ្នែកទទួលផលកម្មចាស់ ពីអតីត មិនថាជាតិនេះឬក៏ជាតិមុន មួយផ្នែកទៀតគឺការធ្វើកម្មថ្មីទាំងកុសលកម្មនិងអកុសលកម្ម ។

## ៧. *លាភដ៏ប្រសើរបំផុត*

ការបានស្តាប់ព្រះធម៌ជាពេលដែលប្រសើរបំផុត ប្រសើរជាងបានលាភណាៗ ទាំងអស់ ព្រោះលាភនាំឲ្យមានការជាប់ជំពាក់តែលាភគឺការបានស្តាប់ព្រះធម៌នាំឲ្យមានការយល់ត្រូវឃើញត្រូវ ។

## ៨. *សេចក្តីពិតនៃជីវិត*

ជីវិតចែកចេញជា ២ ផ្នែក គឺរូបធម៌ និងនាមធម៌ ដោយបរមត្ថមាន ៤ បានដល់ ចិត្ត ចេតសិក រូប និព្វាន តែជីវិតប្រចាំថ្ងៃយើងគ្រប់គ្នាមានបរមត្ថ ៣ វៀរនិព្វានបរមត្ថចេញ ។

## ៩. *មង្គលជីវិត*

មង្គលមិនមែននៅនឹងឈ្មោះតែនៅក្នុងចិត្តដែលល្អស្អាតចិត្តជាកុសលពេលណាពេលនោះជាមង្គល បើចិត្តជាអកុសល ជាអពមង្គល ។

## ១០. *ការលះ*

លះអកុសលចម្រើនកុសល លះការយល់ខុសចម្រើនការយល់ត្រូវលះការមិនដឹងចម្រើនការដឹង លះបាបចម្រើនបុណ្យ ។

## ១១. *សម្បត្តិដ៏មានតម្លៃ*

មាសពេជ្រទ្រព្យសម្បត្តិ ក្នុងលោកប្រមាណតម្លៃបាន តែបញ្ញាដែលយល់ដឹងឃើញច្បាស់សច្ចៈធម៌ប្រមាណតម្លៃ មិនបានឡើយ ។

## ១២. *ជួយអ្នកដទៃឲ្យយល់ធម៌*

ជួយអ្នកដទៃដោយវត្ថុសម្ភារៈបច្ច័យ ៤ ល្អហើយ តែ បើមានឱកាសជួយឲ្យអ្នកដទៃបានយល់ធម៌ល្អជាទីបំផុត ព្រោះបានបើកផ្លូវឲ្យអ្នកនោះបានរួចចាកទុក្ខ ។

## ១៣. *ការស្តាប់ព្រះធម៌*

ពេលដែលបានស្តាប់ព្រះធម៌ពេលនោះ បើកឱកាសឲ្យកុសលចិត្តកើតឡើងបាន ។

## ១៤. *ជីវិតមិនទៀង*

ថ្ងៃនេះមានសេចក្តីសុខសប្បាយ មិនយូរប៉ុន្មានមានសេចក្តីទុក្ខមកដល់ ការលះលោកនេះទៅកាន់ទីលំបាកជាងលោកនេះក៏បានដែរ ។

## ១៥. *កុសលចិត្តជាមង្គល*

មង្គលមិនមែននៅនឹងឈ្មោះនៅនឹងវត្ថុឬពេលវេលាគឺនៅក្នុងចិត្តដែលជាកុសល ធ្វើល្អដោយ កាយ វាចា ចិត្ត ។

## ១៦. *ការបានជួបព្រះធម៌*

កើតជាមនុស្សមិនគ មិនថ្លង់ប្រសើរហើយ ឃើញរបស់មិនល្អ ឮសម្លេងមិនពិរោះល្អជាងមិនបានឮរហូតអស់មួយជីវិត ការបានឃើញបានជួប បានស្តាប់ព្រះធម៌របស់អ្នកមានបញ្ញាប្រសើរជាទីបំផុត ។

## ១៧. *លោភៈនិងទោសៈ*

លោភៈចូលចិត្តពណ៌ល្អស្អាត សម្លេងពិរោះ រសឆ្ងាញ់ ស្រណុកសុខស្រួល តែបើកើតការធុញ មិនមែនជាលោភៈទេ គឺជាទោសៈ ។

## ១៨. *សេចក្តីទុក្ខផ្លូវចិត្ត*

សេចក្តីទុក្ខផ្លូវចិត្តដែលកើតឡើង មិនបានកើតមកពីអ្នកណាទេ គឺកើតមកពីកិលេសនៅក្នុងចិត្តរបស់យើងហ្នឹងឯង យើងត្រូវសិក្សាអប់រំចម្រើនបញ្ញា ដោយការស្តាប់ព្រះធម៌ សិក្សាព្រះធម៌ ដែលជាផ្លូវរំលត់កិលេស។

សុខឬទុក្ខគឺត្រឹមជួរខណៈចិត្តដែលកើតឡើងហើយរលត់ទៅវិញ ។

# ការស្តាប់ព្រះធម៌យល់មិនថាបន្តិចបន្តួចឈ្មោះថា
# មានព្រះធម៌ជាទីពឹងរួចទៅហើយ

## ១៩. *បញ្ញាគឺជាទីពឹង*

រឿងខ្លះអាចពឹងអ្នកដទៃបាន តែពឹងឲ្យកើតបញ្ញាពឹងមិនបានឡើយ ត្រូវពឹងខ្លួនឯង សិក្សាព្រះធម៌ បដិបត្តិធម៌ ។

## ២០. *ប្រើប្រាស់ទ្រព្យសម្បត្តិ*

ទ្រព្យសម្បត្តិរមែងសម្លាប់អ្នកមិនមានបញ្ញា តែអ្នកមានបញ្ញារមែងប្រើប្រាស់ទ្រព្យសម្បត្តិសាងប្រយោជន៍ សាងបុណ្យបារមីសម្បត្តិដែលពិតគឺ សទ្ធា សីល សុត្តៈ ចាគៈ និងបញ្ញា ។

## ២១. *របស់ដែលប្រសើរបំផុត*

អ្វីដែលប្រសើរបំផុត? ជាអ្នកចេះដឹងច្រើន ជាសាស្ត្រាចារ្យ ជានាយករដ្ឋមន្ត្រី ជាប្រធានាធិបតី អ្វីក៏ដោយខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ បើជាមនុស្សអាក្រក់ក៏នៅតែជាមនុស្សអាក្រក់ដដែល ។

## ២២. *ខ្លួនជាទីពឹងនៃខ្លួន*

មានតែខ្លួនយើងប៉ុណ្ណោះដែលអាចរំលត់កិលេសខ្លួនយើងបាន ដូច្នេះ ទើបយើងមិនត្រូវជាមនុស្សឡេះឡោះប្រមាទមិនបានការនោះទេ ។

# មនុស្សអាក្រក់សូម្បីអង្គុយលើបល្ល័ង្កមាសបល្ល័ង្កពេជ្រ

# ក៏នៅតែជាមនុស្សអាក្រក់

## ២៣. ទ្រព្យក្នុងលោកមាន ២ យ៉ាង

១. ទ្រព្យដែលធ្វើឲ្យសត្វលោកវិលវល់ក្នុងវដ្តសង្សារ បានដល់ លាភ យស សរសើរ សុខ ។

២. ទ្រព្យដែលនាំឲ្យចេញចាកវដ្តបានដល់ សទ្ធាក្នុងព្រះរតនត្រៃ សីល ហិរិ ឱត្តប្បៈ សុត្តៈ ចាគៈ និងបញ្ញា ។

## ២៤. ចំណង់

គិតចង់ឲ្យខ្លួនឯងប្រសើរគ្រាន់បើ ប្រសើរយ៉ាងនេះ ប្រសើរយ៉ាងនោះ ព្រោះមិនដឹងធម្មៈ ដែលកំពុងប្រាកដ ចំណង់នេះជាទុក្ខកង្វល់ នាំឲ្យមានទុក្ខព្រួយ ។

## ២៥. *ការនឹកដល់សេចក្ដីស្លាប់*

ការរលឹកដល់សេចក្ដីស្លាប់ដើម្បីឲ្យឃើញប្រយោជន៍នៃការរស់នៅដោយសេចក្ដីមិនប្រមាទ ហើយចម្រើនកុសលគ្រប់ប្រការ ។

## ២៦. *របស់ដ៏មានតម្លៃបំផុត*

របស់ដ៏ប្រសើរនឹងមានតម្លៃបំផុតគឺបញ្ញានឹងសេចក្ដីល្អដែលជាបច្ច័យឲ្យជួបរបស់ដែលល្អស្អាតនឹងសេចក្ដីសុខ ។

## ២៧. *ការសេពគប់អ្នកអត់បញ្ញា*

ការសេពគប់ជាមួយអ្នកអត់បញ្ញា បុគ្គលពាលមានតែនាំភ័យទុក្ខទោស សេចក្តីក្តៅក្រហាយឲ្យយើង អ្នកដែលប្រាថ្នាសេចក្តីសុខចម្រើនបញ្ញានឹងកុសលធម៌ទាំងឡាយគប្បីគេចចេញពីបុគ្គលពាលដូចជាផ្លូវដែលមានភ័យហើយប្រញាប់គេចចេញដូច្នោះឯង ។

## ២៨. *គ្រប់យ៉ាងនៃជីវិតគឺមិនទៀង*

ជីវិតគឺអនត្តា គ្រប់យ៉ាងនៃជីវិតគឺមិនទៀងមានការបែកធ្លាយទៅជាធម្មតា ដូច្នេះជីវិតគឺសេចក្តីទុក្ខ កើតឡើងមកហើយក៏មានទុក្ខ បើយើងមិនសិក្សាព្រះធម៌របស់ព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់សម្តែងហើយ ក៏មិនដឹងសេចក្តីពិតនៃជីវិត គឺ អនិច្ចំ ទុក្ខំ អនត្តា ។

# ពាលខាងក្រៅគឺមិត្តពាល ពាលខាងក្នុងគឺកិលេសទាំងឡាយ

## ២៩. *ពាក្យថាពុទ្ធោ*

ពុទ្ធោ ឬព្រះពុទ្ធអ្នកត្រាស់ដឹងនូវសេចក្តីពិតជាអ្នកភ្ញាក់ដោយបញ្ញាគឺភ្ញាក់ពីការលង់លក់ក្នុងសង្សារវដ្តព្រោះអវិជ្ជាគឺការមិនដឹងនេះឯង ។

## ៣០. *ការរក្សានូវព្រះសាសនា*

កុដិ សាលា ព្រះវិហារ ចេតិយ ព្រះពោធិព្រឹក្ស មិនអាចធ្វើឲ្យព្រះសាសនាស្ថិតនៅបានឡើយ ការយល់ព្រះធម៌នឹងបញ្ញាប្រព្រឹត្តបដិបត្តិធម៌តែប៉ុណ្ណោះ ទើបអាចរក្សាព្រះពុទ្ធសាសនាឲ្យគង់វង្សនៅបាន ។

**រស់នៅជាមួយនឹងធម្មៈ គឺស្ងប់ក្នុងចិត្តនូវអ្វីៗដែលកើតឡើង មិនថាមានលាភ ឬអត់លាភ កុសលវិបាក ឬអកុសលវិបាក**

## ៣១. *មិនទាស់ចិត្តនឹងការពិត*

ធម៌ពិតគឺស្ងប់ចិត្តចំពោះអ្វីៗដែលកើតឡើង មិនទាស់ចិត្តចំពោះអ្វីៗ ដែលកើតឡើង មិនទាស់ចិត្តនឹងការពិត ។

## ៣២. *ការចម្រើននូវអរិយមគ្គ*

ការចម្រើននូវអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ប្រព្រឹត្តទៅ ដើម្បីកំណត់ដឹងនូវបញ្ចក្ខន្ធរបស់ខ្លួន ។

## ៣៣. *សង្ខារធម៌មិននៅក្រោមការបង្គាប់បញ្ជា*

អ្វីដែលកើតរមែងកើត អ្វីដែលមានរមែងមាន អ្វីដែលរលត់រមែងរលត់ នេះជាលក្ខណៈសង្ខារធម៌ មិននៅក្រោមការបង្គាប់បញ្ជារបស់អ្នកណាឡើយ ។

## ៣៤. *ជីវិតគឺធម្មៈ*

ធាតុដឹងកើតឡើងហើយក៏ឃើញ កើតឡើងហើយក៏គិត កើតឡើងហើយក៏ដឹង កើតឡើងហើយក៏ចាំ ទាំងអស់គឺជាធម្មៈ ។

## ៣៥. *ជីវិតគឺជាអ្វី*

ជីវិតប្រចាំថ្ងៃគឺសភាវធម៌តាមផ្លូវកាយ ត្រចៀក ច្រមុះដែលមិនមែនជាតួខ្លួន ។

## ៣៦. *ការមិនដឹង*

ការមិនដឹងដ៏យ៉ាងក្រៃលែង គឺមិនដឹងថាគឺនេះទុក្ខ នេះជាហេតុនៃសេចក្តីទុក្ខ នេះជាផ្លូវរំលត់ទុក្ខ មិនដឹងសង្ខារធម៌ទាំងពួង មិនទៀងជាទុក្ខជាអនត្តា ។

## ៣៧. *ជីវិតពិត*

គឺខណៈនេះកំពុងឃើញ កំពុងដឹងក្លិន ដឹងរស ដឹងក្តៅដឹងត្រជាក់ ប៉ះខ្ទប់សម្ផស្ស ពេញចិត្ត ទាស់ចិត្តក្នុងខណៈនេះឯង ។

## ៣៨. *ធម៌អប់រំចិត្ត*

អកុសលធម៌ទាំងឡាយមិនបានធ្វើឲ្យប្រទេសជាតិរុងរឿងចម្រើន តែប្រទេសជាតិរុងរឿងចម្រើនព្រោះកុសលធម៌ទាំងឡាយចម្រើនឡើង ។

## ៣៩. *មេត្តាធម៌*

ប្រទេសជាតិមិនសុខស្ងប់រៀបរយព្រោះខ្វះធម៌មេត្តា បើខ្វះធម៌មេត្តាមានតែការគំរាមកំហែងព្យាបាទបៀតបៀនគ្នា ។

## ៤០. បុណ្យគឺខណៈចិត្តដែលល្អស្អាត

គឺសេចក្ដីល្អចិត្តដែលជាកុសលជាចិត្តដែលល្អជាទីបំផុត កុសលក្នុងការឲ្យទាន អនុគ្រោះប្រយោជន៍ឲ្យដល់អ្នកដទៃជាដើម ។

## ៤១. វិបាកជាផលរបស់កម្ម

វិបាកជាផលរបស់កម្មរបស់ខ្លួនគ្រប់គ្នាមានកម្មរបស់ខ្លួនដែលបានធ្វើហើយ កម្មជាបច្ច័យឲ្យកើតវិបាកដូច្នេះមិនគួរក្ដៅក្រហាយចំពោះផលរបស់អកុសលកម្មគ្រប់យ៉ាងជាផលរបស់កម្មអ្នកចាត់ចែង វិបាកចិត្តទទួលផលកម្ម ដោយដឹងអារម្មណ៍ដែលប៉ះខ្ទប់ តាមភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ។

## ៤២. សិក្សាព្រះធម៌ដើម្បីឲ្យដឹងថានៅមានកិលេស

អ្នកឆ្លាតនៅក្នុងលោកតែនៅមិនទាន់អស់កិលេស មិនអាចរំលត់កិលេសបាន កិលេសនៅក្នុងចិត្តរបស់បុគ្គលម្នាក់ស្ទើរយក្នុងគឺរាងកាយសម្បូរដោយកិលេស កិលេសគ្រប់ប្រភេទកើតឡើងព្រោះសន្សំតមកពីអតីតជាតិ ។

## ៤៣. សង្ខារធម៌ទាំងឡាយមិនទៀង

សង្ខារធម៌ទាំងឡាយជាសភាវធម៌មានបច្ច័យតាក់តែងកើតឡើង ការកើតឡើងហើយមិនទៀង ការកើតឡើងមិនទៀងនោះជាទុក្ខជាអនត្តា ។

## ៤៤. *ធម្មៈជារបស់ពិត*

បរមត្ថធម៌មកពីភាសាបាលី ៣ ពាក្យគឺ បរម+ អត្ថ+ ធម្ម **បរម** ប្រែថា យ៉ាងក្រៃលែង បរម+អត្ថ+ធម្ម= ធម៌ជារបស់ពិតដ៏យ៉ាងក្រៃលែង ឃើញមានពិតឬអត់? បើមានពិតក៏ជាបរមត្ថធម៌ ។

## ៤៥. *ខណៈដែលយល់សប្តិជាមនោវិញ្ញាណវិថី*

ខណៈដែលយល់សប្តិជាមនោវិញ្ញាណវិថីចិត្ត គិតតាមសញ្ញាការចាំដែលជារឿងយល់សប្តិ តាមផ្លូវមនោទ្វារ ខណៈយល់សប្តិជាអកុសលចិត្តឬកុសលចិត្តក៏បាន ភ្ញាក់ឬក៏លក់ជាអនត្តាគ្រប់ៗខណៈ ការភ្ញាក់ឡើងក៏ឃើញឆាកល្ខោនលោកផ្លូវភ្នែក មានអារម្មណ៍ជាតួសម្តែងល្ខោនហើយក៏លក់ទៅក្នុងរោង នោះគឺជាការលក់ក្នុងភវង្គ ។

## ៤៦. *សិក្សាព្រះធម៌ដើម្បីលះកិលេស*

អ្នកធ្វើអកុសលក៏ត្រូវទទួលផលរបស់អកុសលខ្លួនឯង មិនមានអ្នកណាទទួលជំនួសបាន មិនមាននរណាម្នាក់អាចលះកិលេសឲ្យយើងបានឡើយ ក្រៅពីបញ្ញាដែលចម្រើនឡើង ។

## ៤៧. *ជីវិតជាក្រសែរបស់ចិត្ត*

កើតរលត់មួយខណៈៗរហូត តាំងតែកើតរហូតដល់ស្លាប់ពីមួយជាតិទៅមួយជាតិ កិលេសគ្រប់យ៉ាងដែលកើតឡើងនោះ ព្រោះសន្សំយូរហើយតាំងពីអតីត កាលបើបញ្ញានៅមិនទាន់ចម្រើនឡើងរហូតដល់ថ្នាក់រំលត់កិលេស កិលេសក៏នៅកើតទៀតតទៅក្នុងអនាគត ។

ធម្មៈគឺអ្វី? គឺគ្រប់យ៉ាងដែលមានពិតបែងចែកជា ២ យ៉ាង

១. បរមត្ថធម៌ សភាវធម៌ដែលពិតមិនប្រែប្រួល

២. បញ្ញត្តិធម៌ សភាវដោយសន្មតិ

## *៤៨. ជីវិតគឺមិននៅក្រោមការបង្គាប់បញ្ជា*

ជីវិតគឺគ្រប់យ៉ាងដែលកើតឡើងតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនថាកំពុងឃើញ កំពុងឮ កំពុងដឹងរស ប៉ះខ្ទប់ផ្លូវកាយ ត្រជាក់ ក្តៅ រឹង តឹង ទន់ កម្រើក ញ័រ ជាសុខ ជាទុក្ខ ពេញចិត្ត មិនពេញចិត្ត ច្រណែន កំណាញ់ ។ល។ គ្រប់យ៉ាងជាធម្មៈព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា **សព្វេ ធម្មា អនត្តា** ធម៌ទាំងឡាយ ជាអនត្តា គឺគ្រប់យ៉ាងមិនស្ថិតនៅក្រោមអំណាចបង្គាប់បញ្ជាអ្នកណា កើតឡើងព្រោះហេតុបច្ច័យ តែយើងអាចចម្រើនសតិ រលឹកដឹងថាមិនមែនសត្វ មិនមែនបុគ្គល មិនមែនតួខ្លួន ។

## ៤៩. ពាក្យថាស្ងប់

ពាក្យថាស្ងប់គឺស្ងប់ចាកអកុសលចិត្តក្នុងខណៈនោះ មិនប្រកបដោយអកុសលចេតសិក គឺលោភៈ មោហៈ ទោសៈ ចិត្តដែលស្ងប់គឺ កុសលចិត្ត សេចក្តីស្ងប់ដោយទាន ឬដោយវិរតិ ការវៀរចាកប្រព្រឹត្តនូវទុច្ចរិតផ្លូវកាយ និងវាចា ដោយសីល ឬស្ងប់ក្នុងសមថវិបស្សនា ភាវនាកុសល គឺ សមថនិងវិបស្សនាត្រូវស្ងប់ដោយការយល់ឃើញត្រូវ តាមលំដាប់របស់បញ្ញា មិនថាសមថឬវិបស្សនា ជាសេចក្តី ស្ងប់ឃើញទោសរបស់អកុសល ។

## ៥០. *សេចក្តីប្រាថ្នានៅក្នុងធម៌*

### បុនព្វសុស្សូត្រ បិដកលេខ ៣០ ទំព័រ ២១៨

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត ជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯងព្រះមានព្រះភាគទ្រង់ពន្យល់ណែនាំពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ពួកភិក្ខុនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្តប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងសោតប្រសាទប្រុងស្តាប់ព្រះធម៌ ។

គ្រានោះឯង យក្ខិនីឈ្មោះបុនព្វសុមាតា លួងកូនតូច យ៉ាងនេះថា :

**តុណ្ហី ឧត្តរិកេ ហោហិ  តុណ្ហី ហោហិ បុនព្វសុ**

**យាវាហំ ពុទ្ធសេដ្ឋស្ស  ធម្មំ សោស្សាមិ សត្ថុនោ ។**

ម្នាលនាងឧត្តរា ចូរកូនស្ងៀមទៅម្នាលបុនព្វសុ ចូរកូនស្ងៀមទៅ ម៉ែនឹងស្តាប់នូវព្រះធម៌ របស់ព្រះសាស្តាជាព្រះពុទ្ធ ដ៏ប្រសើរសិន ។

**និព្វានំ ភគវា អាហ        សព្វគន្ថប្បមោចនំ**

**អតិវេលា ច មេហោតិ អស្មិំ ធម្មេ បិយាយនា ។**

ព្រះមានព្រះភាគ បានសម្តែងព្រះនិព្វាន ថា ជាគ្រឿងរួចចាកគន្លងធម៌ទាំងពួង ម្យ៉ាងទៀត សេចក្តីប្រាថ្នាក្នុងធម៌នោះរបស់ម៉ែខ្លាំងហួសប្រមាណ ។

**បិយោ លោកេ សកោ បុត្តោ បិយោ លោកេ សកោ បតិ**

**តតោ បិយតរំ មយ្ហំ        អស្ស ធម្មស្ស មគ្គនា ។**

កូនរបស់ខ្លួន ក៏ជាទីស្រលាញ់ក្នុងលោក ប្តីរបស់ខ្លួនក៏ជាទីស្រឡាញ់ក្នុងលោក តែសេចក្តីប្រាថ្នាក្នុងធម៌នោះ ជាទីស្រឡាញ់របស់ម៉ែក្រៃលែងជាងនោះទៅទៀត ។

**ន ហិ បុត្តោ បតិ វាបិ   បិយោ ទុក្ខាបមោចយេ**

**យថា សទ្ធម្មស្សវនំ   ទុក្ខា មោចេតិ បាណិនំ ។**

កូនក្តី ប្តីក្តី ដែលជាទីស្រឡាញ់ មិនមែនរំដោះម៉ែឲ្យរួចចាកទុក្ខបានទេ មានតែកាស្តាប់នូវព្រះធម៌ ទើបរំដោះសត្វទាំងឡាយឲ្យរួចចាកទុក្ខបាន ។

**លោកេ ទុក្ខបរេតស្មឹ ជរាមរណសំយុត្តេ**

**ជរាមរណមោក្ខាយ យំ ធម្មំ អភិសម្ពុធំ**

**តំ ធម្មំ សោតុមិច្ឆាមិ ត្វំណ្ឌី ហោហិ បុនព្វសុតិ ។**

កាលបើសត្វលោកត្រូវសេចក្ដីទុក្ខគ្រប់សង្កត់ ប្រកបដោយជរានិងមរណៈហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយនូវធម៌ណា ម៉ែចង់ស្ដាប់ធម៌នោះ ដើម្បីរួចចាកជរានិងមរណៈ ម្នាលបុនព្វសុ ចូរកូនស្ងៀមទៅ ។

បុនព្វសុកុមារ តបថា ៖

**អម្ម ន ព្យាហរិស្សាមិ    តុណ្ហីភូតាយមុត្តរា**

**ធម្មមេវ និសាមេហិ    សទ្ធម្មស្សវនំ សុខំ ។**

បពិត្រអ្នកម៉ែ ខ្ញុំមិននិយាយទេ ទាំងនាងឧត្តរានេះក៏ស្ងៀមដែរ សូមអ្នកម៉ែស្តាប់ធម៌ចុះ ការស្តាប់ព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ ។

**សទ្ធម្មស្ស អនញ្ញាយ ធម្មំ ទុក្ខំ ចរាមសេ**

**ឯស ទេវមនុស្សានំ សម្ពុទ្ធានំ បភង្ករោ**

**ពុទ្ធោ អន្តិមសារីរោ ធម្មំ ទេសេតិ ចក្ខុមាតិ ។**

បពិត្រអ្នកម៉ែ យើងដើរទាំងទុក្ខ ព្រោះមិនបានដឹងនូវព្រះសទ្ធម្ម ព្រះពុទ្ធអង្គនោះ ជាអ្នកធ្វើនូវពន្លឺដល់ទេវតានិងមនុស្សទាំងឡាយដែលវង្វេង ព្រះអង្គមានព្រះសរីរៈជាទីបំផុត មានបញ្ញាចក្ខុ ទ្រង់កំពុងសម្តែងធម៌ ។ (ម៉ែនិងកូនប្រុសបានសម្រេចសោតាបត្តិផល ឯនាងឧត្តរា ជាកូនស្រីក៏មានឧបនិស្ស័យដែរ តែមិនទាន់បានសម្រេច ព្រោះនៅតូចពេក ទទួលធម្មទេសនាមិនបាន ។ អដ្ឋកថា ។) ។

បុនព្វសុមាតាពោលថា :

**សាធុ ខោ បណ្ឌិតោ នាម បុត្តោ ជាតោ ឧរេ សយោ**

**បុត្តោ មេ ពុទ្ធសេដ្ឋស្ស ធម្មសុទ្ធំ បិយាយតិ ។**

ប្រពៃណាស់ហ្ន៎ កូនកើតហើយ ដេកនៅនាទ្រូងម៉ែ គឺជាបណ្ឌិត កូនរបស់ម៉ែស្រឡាញ់ធម៌ដ៏បរិសុទ្ធរបស់ព្រះពុទ្ធដ៏ប្រសើរ ។

**បុនព្វសុ សុខី ហោហិ អជ្ជាហម្ហិ សមុគ្គតា**

**ទិដ្ឋានិ អរិយសច្ចានិ ឧត្តរាបិ សុណាតុ មេតិ ។**

ម្នាលបុនព្វសុ ចូរកូនបានសុខស្រួល ម៉ែបានខ្ពង់ខ្ពស់ (ក្នុងសាសនា) តាំងពីថ្ងៃនេះហើយ ទាំងនាងឧត្តរា ក៏ចូរស្តាប់អរិយសច្ចៈទាំងឡាយ ដែលម៉ែនិងកូនបានឃើញហើយចុះ ។

# សទ្ធម្មស្សវនំ សុខំ

# ការស្តាប់នូវព្រះសទ្ធម្មនាំមកនូវសេចក្តីសុខ ។

## ៥១. *ប្រយោជន៍នៃការស្តាប់ព្រះធម៌*

ការស្តាប់ព្រះធម៌គឺជាការអប់រំទូន្មានចិត្ត គឺជាការប្រដៅចិត្ត ការគ្រប់គ្រងចិត្ត នាំចិត្តឲ្យរួចចាកអកុសលទាំងឡាយទាំងពួង ។

## ៥២. *ត្រឹមតែរូបធម៌និងនាមធម៌*

សភាវធម៌ដែលប្រកាន់មាំថា ជាសត្វជាតួខ្លួនជាយើងជាគេនោះត្រឹមជានាមធម៌និងរូបធម៌ដែលសន្មតិហៅឈ្មោះតាមអាការៈដែលប្រាកដផ្សេងៗគ្នាប៉ុណ្ណោះ តែការពិតក៏ជាសភាវធម៌មួយប្រភេទៗ កើតឡើងព្រោះបច្ច័យកើតរលត់ៗជារឿយៗ ។

## ៥៣. *សភាវធម៌ដែលប្រព្រឹត្តទៅគ្រប់ៗខណៈគឺជាអភិធម្ម*

គម្ពីរព្រះអភិធម្មបិដកគឺជាពាក្យប្រៀនប្រដៅរបស់ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងបរមត្ថធម៌ ៤ ប្រការ គឺចិត្ត ចេតសិក រូប និព្វាន ដែលមាននៅក្នុងជីវិតមនុស្សយើងគ្រប់ៗគ្នា គឺ ចិត្ត ចេតសិក រូប ជាសភាវដឹងជាធំ ជាប្រធាននៃការដឹង ចេតសិកគឺជាសភាវធម៌ដែលកើតរួមជាមួយចិត្ត រលត់ព្រមជាមួយចិត្ត ដឹងថាអារម្មណ៍ជាមួយចិត្ត រូបជាសភាវមិនដឹងអារម្មណ៍ បរមត្ថធម៌ទាំង ៣ ប្រព្រឹត្តទៅក្នុងជីវិតរបស់មនុស្សយើងគ្រប់ៗខណៈ ដូចខណៈដែលឃើញតាមផ្លូវភ្នែក ចិត្តធ្វើកិច្ចឃើញ ចេតសិកក៏កើតរួមជាមួយ ជាដើម ។

## ៥៤. ស្តាប់ព្រះធម៌ដោយការគោរពតាំងចិត្ត

ការស្តាប់ព្រះធម៌ដោយសេចក្តីគោរព តាំងចិត្តស្តាប់ជាការគោរពព្រះធម៌ ការសន្សំការយល់ទៅជាតិមុខ ការប្រកាន់ខ្លួនគឺមានះ ខណៈដែលមានមានះគឺខ្វះមេត្តា មេត្តាចម្រើនប៉ុណ្ណាសេចក្តីក្រោធក៏ថយចុះប៉ុណ្ណោះដែរ ។

## ៥៥. ផ្លូវតែមួយនៃការរួចចាកទុក្ខ

ផ្លូវដែលនឹងឈ្នះចិត្តខ្លួនឯងគឺឈ្នះកិលេស គឺការអប់រំចម្រើនសតិប្បដ្ឋាន គ្រប់យ៉ាងគឺជាធម្មៈ សូម្បីក្នុងខណៈដែលកិលេសកើតឡើង គម្បីយល់ថាជាធម៌មិនមែនយើង នេះគឺជាផ្លូវនៃការរំលត់នូវកិលេសការអប់រំចម្រើនសតិប្បដ្ឋានរលឹកសភាពធម្មៈក្នុងខណៈនេះថា ជាធម៌មិនមែនយើង ផ្តើមដោយការស្តាប់ឲ្យយល់ថា ធម្មៈ គឺអ្វី?

## ៥៦. *កម្មជាហេតុឲ្យកើតផលគឺវិបាក*

កម្មណាដែលធ្វើហើយក៏ជាហេតុឲ្យកើតផលគឺវិបាក ដល់អ្នកដែលធ្វើកម្មនោះតាមសមគួរដល់ឱកាសរបស់កម្មនោះៗ អ្នកធ្វើកម្មទើបសមគួរទទួលផលរបស់កម្ម មានកម្មជាកំណើតគឺជាហេតុឲ្យកើតក្នុងសុគតិភូមិឬទុគតិភូមិ ។

## ៥៧. *បើមិនកើតក៏មិនមានទុក្ខព្រោះទុក្ខមានព្រោះការកើត*

បើមិនកើតក៏មិនមានទុក្ខ ដូចជាទុក្ខផ្លូវកាយ និងផ្លូវចិត្ត និងមានការកើត ព្រោះមានកិលេស ដូច្នេះហេតុឲ្យកើតទុក្ខ គឺអវិជ្ជា ខណៈដែលចិត្តមិនស្ងប់ជាអកុសល ការរំលត់កិលេសជាហេតុនៃការរំលត់ទាំងអស់ ។

## ៥៨. *បណ្ឌិតហៅអ្នកនោះថាជាមិនក្រខ្សត់*

ម្នាលភិក្ខុទាំងឡាយទ្រព្យ៧ ប្រការនោះឯងទ្រព្យគឺ សទ្ធា សីល ហិរិ ឱត្តប្បៈ សុត្តៈ ចាគៈ និងបញ្ញា ទ្រព្យពួកនេះ មានដល់អ្នកណាជាបុរសក៏ដោយជាស្ត្រីក៏ដោយ បណ្ឌិត ហៅអ្នកនោះថាជាអ្នកមិនក្រខ្សត់ ជីវិតរបស់អ្នកនោះមិន អត់ប្រយោជន៍ ព្រោះហេតុដូច្នោះហើយអ្នកមានបញ្ញាការ រលឹកដល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយគប្បី ប្រកបដោយសទ្ធា សីល និងសេចក្ដីជ្រះថ្លា ។

## ៥៩. នេះគឺទ្រព្យគឺបញ្ញា

ម្នាលភិក្ខុទាំងឡាយទ្រព្យ ៧ ប្រការនេះគឺ សទ្ធា សីល ហិរិ ឱត្តប្បៈ សុត្តៈ ចាគៈ បញ្ញា ម្នាលភិក្ខុទាំងឡាយទ្រព្យគឺបញ្ញាតើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយអរិយសាវកក្នុងធម្មវិន័យនេះប្រកបដោយបញ្ញាដែលកំណត់ការកើតនិងការរលត់ នេះហៅថាទ្រព្យគឺបញ្ញា ។

## ៦០. *ព្រះអភិធម្មគឺជាពាក្យប្រៀនប្រដៅដែលជាប់ទាក់ទងនឹងសច្ចៈធម៌*

កម្មដែលយើងធ្វើទុក្ខហើយជាហេតុឲ្យបានលាភ អត់លាភ បានយស អត់យស សរសើរ និន្ទា សុខ ទុក្ខ សិក្សាព្រះធម៌ដោយល្អិត ព្រះអភិធម្មជាពាក្យប្រៀនប្រដៅ ដែលជាប់ទាក់ទងនឹងពាក្យប្រៀនប្រដៅដែលមានពិត ព្រះសម្មាសម្ពុទ្ធទ្រង់សន្សំបារមី ៤ អសង្ខេយ្យ និង ១ សែនកប្បដើម្បីត្រាស់ដឹងនូវសច្ចៈធម៌ គឺសេចក្ដីពិតទាំងពួងនេះឯង ។

## ៦១. *កុសលទាំងឡាយគួរចម្រើន*

កុសលថ្នាក់សីលក៏គួរចម្រើន កុសលថ្នាក់សេចក្ដីស្ងប់ក៏គួរចម្រើនគឺមានមេត្តា ករុណា និង ឧបេក្ខា ដល់អ្នកដទៃ រលឹកដល់គុណព្រះមានព្រះភាគ គុណរបស់ព្រះធម៌ គុណរបស់ព្រះសង្ឃ រលឹកដល់ពាក្យប្រៀនប្រដៅដែលនាំឲ្យចិត្តផុតពីសេចក្ដីលោភ សេចក្ដីក្រោធនិងការវង្វេង ខណៈនោះជាកុសលថ្នាក់ស្ងប់ ជាការអប់រំសមថក្នុងជីវិតប្រចាំថ្ងៃ ។

## ៦២. *ព្រះអភិធម្មមិនមែននៅក្នុងគម្ពីរ*

ព្រះអភិធម្មមិនមែននៅក្នុងគម្ពីរគឺនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងនេះឯង គឺចិត្តឃើញ ចិត្តឮ ចិត្តដឹងក្លិន ចិត្តដឹងរស ចិត្តនឹកគិត នឹងចេតសិកផ្សេងៗ ដែលកើតរួម និងរូបផ្សេងៗនៅហ្នឹងខ្លួនយើង មហាភូតរូប ឧបាទាយរូប ជាដើម ចំណែកព្រះនិព្វាន គឺជាលោកុត្តរចិត្ត ចិត្តដែលផុតចាកលោកនេះ ។

# ដរាបណានៅមានតណ្ហាក៏ត្រូវមានទុក្ខជាធម្មតា

**៦៣**. *ព្រះពុទ្ធសាសនា* ជាសាសនាប្រៀនប្រដៅឲ្យចម្រើនបញ្ញា បើមិនមានបញ្ញា គឺមិនអាចប្រហារកិលេសបាន បញ្ញាកើតឡើងដោយអាស្រ័យការស្តាប់

*បរមត្ថធម៌ណាជាសង្ខតធម៌ ?*

ចិត្តបរមត្ថ ចេតសិកបរមត្ថ រូបបរមត្ថ ជាសង្ខតធម៌ ព្រោះមានបច្ច័យឲ្យកើតឡើង ចំណែកនិព្វានបរមត្ថជាអសង្ខតធម៌ ព្រោះជាធម៌ដែលមិនមានបច្ច័យតាក់តែងឲ្យកើតឡើង ។

## អកុសលចិត្ត ៣ ប្រភេទ

**១. លោភៈមូលចិត្ត** ចិត្តដែលប្រកបដោយសេចក្តីត្រូវការ សេចក្តីត្រេកអរ ជាប់ជំពាក់ ។

**២. ទោសៈមូលចិត្ត** ចិត្តដែលប្រទូសរ៉ាយ មិនពេញចិត្ត មិនសប្បាយចិត្ត ។

**៣. មោហៈមូលចិត្ត** គឺអកុសលចិត្តដែលមិនប្រកបដោយលោភៈនិងទោសៈមានលក្ខណៈវង្វេង ។

## ៦៤. ផ្លូវតែមួយគត់នាំទៅកាន់ទីរំលត់ទុក្ខ

ការពិចារណាកាយក្នុងកាយ វេទនាក្នុងវេទនា ចិត្តក្នុងចិត្ត នឹងធម៌ក្នុងធម៌ គឺការមិនឃើញកាយ វេទនា ចិត្ត ធម៌ ថាជាតួខ្លួន សតិរលឹកដឹងលក្ខណៈរបស់រូបធម៌ និងនាមធម៌ ដែលកំពុងប្រាកដក្នុងជីវិតប្រចាំថ្ងៃ សភាវធម៌ទាំងនោះមិនទៀងជាទុក្ខ ជាអនត្តា ផ្លូវនេះឯងគឺជាផ្លូវនៃការរំលត់ទុក្ខ ។

## ៦៥. *បុគ្គល៥ជំពូកនេះជាអ្នកត្រូវទៅកាន់អបាយ*

ជាអ្នកត្រូវទៅកាន់អបាយ ត្រូវធ្លាក់នរកក្តៅក្រហាយកែខៃមិនបាន គឺបុគ្គលសម្លាប់មាតា១ សម្លាប់បិតា១ សម្លាប់មាតា១ មានចិត្តប្រទូសរ៉ាយធ្វើលោហិតព្រះសម្មាសម្ពុទ្ធឲ្យចេញ១ បំបែកសង្ឃ១ បុគ្គល៥ ពួកនេះឯង ជាអ្នកត្រូវទៅកាន់អបាយភូមិ ។

## ៦៦. *បាបមិត្តរបស់ចិត្ត*

បាបមិត្តរបស់ចិត្តមានលោភៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ សេចក្តីច្រណែន កាមឆន្ទះនិងព្យាបាទជាដើម ព្រោះហេតុដូច្នោះ ត្រូវប្រញាប់ហាមឃាត់ចិត្ត អូសទាញចិត្ត មិនឲ្យធ្លាក់ចូលក្នុងអន្លង់បាបកម្មឡើយ ។

## ៦៧. *ហេតុដែលនាំឲ្យអាយុវែង៥ប្រការ*

ធម៌៥ ប្រការជាហេតុនាំឲ្យអាយុវែងគឺ បុគ្គលអ្នកធ្វើសេចក្ដីសប្បាយឲ្យដល់ខ្លួនឯង១ អ្នកដឹងប្រមាណក្នុងទីសប្បាយ១ បរិភោគអាហារដែលរលាយងាយ១ ជាអ្នកត្រាច់ទៅក្នុងកាលដ៏សមគួរ១ ជាអ្នកប្រព្រឹត្តដ៏ប្រសើរ១ ធម៌៥ ប្រការនេះជាហេតុនាំឲ្យអាយុវែង ។

## ៦៨. *សទ្ធាជាមិត្តពិត*

សទ្ធាជាកល្យាណមិត្ត ព្រោះសទ្ធាអាចរំដោះយើងឲ្យរួចពីកិលេស សទ្ធានាំឲ្យយើងឆ្លងពីអន្លង់ទាំង ៤ បាន ។

## ៦៩. ហេតុដែលនាំឲ្យអាយុខ្លី៥ប្រការ

ធម៌៥ ប្រការជាហេតុនាំឲ្យអាយុខ្លីគឺ បុគ្គលមិនធ្វើសេចក្តីសប្បាយដល់ខ្លួនឯង១ បុគ្គលមិនដឹងប្រមាណក្នុងទីសប្បាយ១ បរិភោគអាហារដែលមិនងាយរលាយ១ ជាអ្នកត្រាច់ទៅក្នុងទីមិនសមគួរ១ ជាអ្នកប្រព្រឹត្តមិនប្រសើរ១ ធម៌៥ ប្រការនេះជាហេតុនាំឲ្យអាយុខ្លី ។

# សទ្ធាយ តវតិ ឱយំ

សត្វដែលឆ្លងអន្លង់បានដោយសារសទ្ធា ។

## ៧០. *បុណ្យជាមិត្តល្អ*

បុណ្យជាមិត្តល្អ ព្រោះនាំសេចក្ដីសុខមកឲ្យ ទាំងក្នុងលោកនេះនិងទាំងក្នុងលោកខាងមុខ ។

## ៧១. *មានធម៌ជាកោះជាទីពឹង*

អ្នកទាំងឡាយចូរមានខ្លួនជាកោះ មានខ្លួនជាទីពឹង កុំមានវត្ថុអ្វីដទៃជាទីពឹង គឺមានធម៌ជាកោះមានធម៌ជាទីពឹង ។

## ៧២. *ការអប់រំចិត្តប្រព្រឹត្តទៅក្នុងភាវនា*

កុសលដែលប្រព្រឹត្តទៅក្នុងភាវនាគឺការអប់រំចិត្តបានដល់ធម្មស្សវនការស្ដាប់ព្រះធម៌ ធម្មទេសនាមយការសម្ដែងព្រះធម៌ ភាវនាមយការអប់រំចម្រើនសមថភាវនាឬវិបស្សនាភាវនា ។

## ៧៣. *កុសលដែលប្រព្រឹត្តទៅក្នុងទានមាន៣យ៉ាង*

**១.ទានមយ** បុណ្យសម្រេចដោយការឲ្យទាន ។

**២.បត្តិទានមយ** បុណ្យសម្រេចដោយការឧទ្ទិសដល់អ្នកដទៃអនុមោទនា ។

**៣.បត្តានុមោទនាមយ** បុណ្យសម្រេចដោយការអនុមោទនាកុសលអ្នកដទៃ ។

## ៧៤. *ព្រះអនាគាមិបុគ្គលរំលត់ទោសៈបាន*

អ្នកដែលរំលត់ទោសៈបាន គឺអ្នកដែលរំលត់សេចក្ដីពេញចិត្តក្នុង រូបសម្លេង ផោដ្ឋព្វៈ អ្នកនោះត្រូវដឹងច្បាស់អរិយសច្ចៈធម៌ ។

## ៧៥. *ការឃើញច្បាស់ធម៌*

ការឃើញច្បាស់ធម៌ជាការឃើញច្បាស់លក្ខណៈសភាវធម៌ដែលជាអនត្តា មិននៅក្នុងអំណាចការបង្គាប់បញ្ជារបស់អ្នកណា ។

## ៧៦. *មិនដឹងសភាវធម៌ជាទុក្ខ*

អារម្មណ៍គឺចិត្តដែលកំពុងដឹង នាមធម៌ដឹងអារម្មណ៍នឹកគិតរឿងផ្សេងៗ បើគិតត្រូវក៏ជាកុសលមានសេចក្ដីសុខ បើគិតមិនល្អគិតខុសនាំឲ្យកើតទុក្ខ ការមិនដឹងសភាវធម៌នាំឲ្យកើតទុក្ខ ។

## ៧៧. *សេពគប់សទ្ធា*

ព្រោះសទ្ធា ហិរិ ឱត្តប្បៈ ជាដើមនាំឲ្យយើងបានខ្ពង់ខ្ពស់ នាំឲ្យយើងបាននូវបញ្ញា រួចអំពីអកុសលធម៌គ្រប់យ៉ាង ។

## ៧៨. *ភ្ញាក់ឬកំពុងលក់ជាអនត្តា*

ខណៈយល់សប្តិជាមនោវិញ្ញាណវិថីចិត្ត គឺគិតតាមសញ្ញាការចាំដែលជារឿងយល់សប្តិផ្លូវមនោទ្វារ ភ្ញាក់ឬលក់ក៏ជាអនត្តាគ្រប់ៗ ខណៈ ខណៈដែលយល់សប្តិជាកុសលចិត្តឬអកុសលចិត្តក៏បាន ។

## ៧៩. *វង្វេងនឹងជីវិត*

ការមិនដឹងសេចក្តីពិតនាំឲ្យចិត្តជាប់ជំពាក់ឬកើតទុក្ខក្នុងរឿងរ៉ាវផ្សេងៗ បុគ្គលល្ងង់ខ្លៅមានខ្លួនឯងជាសត្រូវ គឺជាកំពូលសត្រូវនឹងខ្លួនឯង ។

## ៨០. *សតិកើតទីណាក៏បាន*

ការអប់រំចម្រើនបញ្ញា សតិកើតទីណាក៏បាន កំពុងឈឺធ្មេញជាលក្ខណៈ រលឹកដឹងជាសភាវដឹង អាការដឹង ការដឹងឈឺមិនមែនធ្មេញ ។

## ៨១. *សិក្សាជម្មៈ*

អារម្មណ៍របស់ចិត្តតាមទ្វារ ៦ គឺរូប សម្លេង ក្លិន រសផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។

### ៨២. *អកុសលគឺជាមេរោគ*

ចិត្តមានអកុសលគឺមានមេរោគ ឬមានជាតិពិស បើចិត្តមានបុណ្យ មានកុសលគឺមានឱសថឬមានថ្នាំសម្រាប់បន្សាបជាតិពិស ។

### ៨៣. *ចិត្តមនុស្សយើងឥទ្ធិពលខ្លាំងណាស់* គឺថា

បើចិត្តនេះយ៉ាងណាលោកនេះក៏ប្រាកដទៅជាយ៉ាងនោះដែរ ការរក្សាចិត្ត ការអប់រំចិត្តជាការងារដ៏សំខាន់ ។

# មិនគួរលះឡើយសេចក្តីល្អក្នុងជីវិតប្រចាំថ្ងៃ

***៨៤. អត់ធន់ធ្វើអ្វី អត់ធន់ដើម្បីអ្វី?*** អត់ធន់ដើម្បីដុតកិលេស អត់ធន់ដើម្បីអប់រំចម្រើនបញ្ញា រហូតដល់រំលត់កិលេសមិនឲ្យកើតទៀតឡើយ ។

## *៨៥. រលឹករឿយៗ*

ដែលគួររលឹករឿយៗ គឺសេចក្ដីស្លាប់ នេះគឺជារឿងសំខាន់ដែលយើងត្រូវរលឹក ដើម្បីសេចក្ដីមិនប្រមាទ ។

**ធម្មបីតិ សុខំ សេតិ** អ្នកមានបីតិក្នុងធម៌តែងដេកជាសុខ

# សេចក្ដីប្រមាទធំយ៉ាងក្រៃលែង គឺការមិនស្ដាប់ព្រះធម៌

## ៨៦. *ការកើតនិងការរលត់*

អ្វីកើត? ធម្មៈកើត អ្វីស្លាប់? ធម្មៈរលត់ ជាការសម្តែងដល់សភាវធម៌កើតឡើងព្រោះហេតុបច្ច័យកើតឡើង ហើយរលត់ទៅ មិនទៀងជាទុក្ខ ។

## ៨៧. *មិត្តដែលមិនគួរសេពគប់*

ព្រះមានព្រះភាគទ្រង់សម្តែងថាលក្ខណៈរបស់មិត្តមិនដែលមិនគួរសេពគប់ គឺអ្នកដែលមិនមានហិរិ និង ឱត្តប្បៈ ។

## ៨៨. *ការស្វែងរកសេចក្តីសុខដើម្បីខ្លួនឯង*

ដោយការឲ្យសេចក្តីសុខដល់អ្នកដទៃ គឺគួរឲ្យសរសើរផងត្រេកអរផង គួរឲ្យគោរពផង ។

# កិច្ចដ៏សំខាន់របស់ពុទ្ធបរិស័ទ គឺការស្តាប់ព្រះធម៌

## ៨៩. មិនសាងក្ដៅក្រហាយ

សូម្បីយើងកំពុងឈឺធ្ងន់ឬពិការខ្វាក់ខ្វិនក៏អាចសម្រេចសេចក្ដីសុខផ្លូវចិត្តបានដែរ ។ ទោះបីយើងក្រលំបាកតោកយ៉ាក ទទួលអកុសលវិបាក ទុក្ខភ័យវិបត្តិ យ៉ាងណាក៏ដោយសម្រាប់យើងម្នាក់ឯងមិនជាអ្វីទេ កុំឲ្យតែមនុស្សសត្វដទៃមានសេចក្ដីទុក្ខដោយសារយើង ។

## ៩០. ការអប់រំចិត្ត

បើយើងមិនរៀនអប់រំចិត្ត មួយថ្ងៃៗ មានតែសេចក្ដីទុក្ខ ចិត្តដែលអប់រំល្អហើយរមែងបាននូវសេចក្ដីសុខ ។

## ៩១. មនុស្សដែលគួរឲ្យសរសើរ

មនុស្សដែលគួរឲ្យសរសើរ គឺមនុស្សដែលបានធ្វើប្រយោជន៍ ដល់ខ្លួនឯង និងសង្គម ។

## ៩២. មនុស្សដែលឆ្លាត

មនុស្សដែលឆ្លាតក្នុងការនិយាយគឺនិយាយមិនឲ្យអ្នកដទៃស្រគៀត្រចៀក ឈឺចិត្តស្អិតទ្រូងដោយសារពាក្យសម្តីរបស់យើង ។

## ៩៣. កើតមកដើម្បីសាងប្រយោជន៍

មនុស្សយើងកើតមកដើម្បីសាងប្រយោជន៍ដើម្បីខ្លួនឯងនិងមនុស្សផងគ្នានិងសត្វទាំងឡាយ ។

## ៩៤. ពន្លឺបញ្ញា

ដួងព្រះអាទិត្យកម្ចាត់បង់នូវភាពងងឹត តែបញ្ញាកម្ចាត់បងនូវមោហៈអវិជ្ជា ពន្លឺអ្វីភ្លឺដោយបញ្ញាមិនមាន ។

## ៩៥. *ព្រះធម៌បន្សាបនូវភាពស្រវឹងជីវិត*

ពេញចិត្តក្នុងការសិក្សាស្តាប់ព្រះធម៌ ជាប្រចាំថ្ងៃព្រោះបានស្ងប់ក្នុងចិត្ត ដូច្នេះសូមកុំធុញទ្រាន់ក្នុងការក្រេបរសព្រះធម៌ឡើយព្រះធម៌បន្សាបនូវភាពស្រវឹង ។

## ៩៦. *អ្នកដែលស្តាប់ព្រះធម៌រមែងចម្រើនទៅ*

*ដោយគុណធម៌* ចម្រើនទៅដោយមេត្តា ករុណា សេចក្តីសន្តោស សេចក្តីព្យាយាម មានសីល មានសមាធិ មានខន្តីជាដើម រមែងកើតឡើងចម្រើនក្នុងចិត្តព្រោះបានស្តាប់ធម៌យល់ ។

## ៩៧. សាងគុណធម៌

ការសាងគុណធម៌ឲ្យចម្រើនក្នុងចិត្តរបស់ខ្លួនឯងផង ជួយអ្នកដទៃឲ្យចម្រើនគុណធម៌ក្នុងចិត្តផង នេះជាប្រយោជន៍ដ៏មានខ្លឹមសារក្នុងជីវិតរបស់មនុស្សយើង ។

## ៩៨. ស្វែងរកសេចក្ដីសុខតាមរយៈផ្លូវចិត្ត

សេចក្ដីសុខដែលកើតក្នុងចិត្តរបស់ខ្លួនឯង ស្ថិតក្នុងខ្លួនឯងជាប្រចាំ ដោយមិនពឹងវត្ថុខាងក្រៅ ដូចជាលាភសក្ការៈ កិត្តិយសកេរ្តិ៍ឈ្មោះការគោរពរាប់អាន និងពាក្យសរសើរជាដើម សេចក្ដីសុខប្រភេទនេះគឺជាសេចក្ដីសុខដែលមានសភាពស្រស់ថ្លា ។

## ៦៩. សមត្ថភាពរបស់មនុស្ស

មនុស្សយើងអាចអប់រំខ្លួនឯងបានរហូតបានដល់ភាពជាកំពូលមនុស្សគឺព្រះសម្មាសម្ពុទ្ធយើងកុំបោះបង់ខ្លួនឯងឲ្យសោះ ត្រូវរស់ជាមួយខ្លួនឯង ស្មោះត្រង់ ថែរក្សារហ្វឹកហាត់អប់រំចម្រើនបញ្ញា ថែរក្សាចិត្តទាល់តែបានជាទីពឹងរបស់ខ្លួនឯង ។

ការលះបង់ លោភៈ មោហៈ ក្នុងចិត្តយើងមិនអាចពឹងអ្នកណាឱ្យលះបង់បានឡើយ គឺត្រូវតែពឹងលើខ្លួនឯង ។

## ១០០. *រីករាយដោយនន្ទិរាគៈជាអន្ទាក់នៃសេចក្ដីទុក្ខសោក*

អ្វីៗទាំងអស់នៅក្នុងលោកដែលយើងរីករាយ បើមិនលះបង់នូវបាបធម៌នៅក្នុងចិត្តយើងបានទេ សុទ្ធតែជាគ្រឿងស្រវឹងគ្រឿងញៀន ជាប់ជំពាក់នាំឲ្យយើងកើតទុក្ខ ។

## ១០១. *កុំមើលងាយបាបថាមានប្រមាណតិច*

ភ្លើងធូបសូម្បីតែតូចក៏អាចដុតផ្ទះឲ្យឆេះបានដែរ លាមកសូម្បីតែបន្តិចបន្តួចក៏ធ្វើឲ្យមានក្លិនស្អុយបានដែរ យ៉ាងណាក៏ដូចគ្នាកុំមើលងាយថាបាបមានប្រមាណតិច ។

## ១០២. *បុគ្គលដែលប្រាសចាកនូវគុណធម៌*

រមែងមានប្រក្រតីរំលាយខ្លួនឯង ដូចច្រែះកើតអំពីដែកណារមែងស៊ីនូវដែកនោះវិញ ។

## ១០៣. *ភ្លើងដុតចិត្ត*

កិលេសកើតពីចិត្តបុគ្គលណា រមែងដុតបុគ្គលនោះ ដូចភ្លើងអាស្រ័យនូវឧសណារមែងដុតកំទេចនូវឧសនោះវិញ ។

## ១០៤. *មេត្តាចិត្ត*

បើចិត្តមានមេត្តាដូចជាស្ថិតនៅក្នុងវិមានប្រាសាទយ៉ាង ដូច្នោះឯងរមែងសុខសប្បាយទូលំទូលាយ មិនមានទោមនស្សចង្អៀតចង្អល់ឡើយ ។

## ១០៥. *មិត្តរមែងរក្សាអាថ៌កំបាំងរបស់មិត្ត*

បើយើងបែកមិត្តសាងសត្រូវ រឿងអាថ៌កំបាំងរមែងបែកធ្លាយ ។

## ១០៦. *កុំចង់ឲ្យគេដូចយើង*

ម៉េចបានគេមិនដូចយើង ព្រោះយើងមិនដូចគេ ព្រោះការសន្សំមិនដូចគ្នា ទាំងឧបនិស្ស័យ ល្អ មិនល្អប្រព្រឹត្តទៅតាមការសន្សំរបស់បុគ្គលម្នាក់ៗរៀងៗខ្លួន បង្គាប់បញ្ជាមិនបាន ។

## *សេចក្តីស្លាប់មាន ៣ យ៉ាង*

**១. ខណិកមរណៈ** បានដល់សេចក្តីស្លាប់មួយខណៈៗ ដែលចិត្ត ចេតសិក រូប កើតឡើងហើយក៏រលត់ទៅ ។

**២. សមតិមរណៈ** បានដល់សេចក្តីស្លាប់របស់សត្វបុគ្គលក្នុងមួយជាតិៗ ។

**៣. សមុច្ឆេទមរណៈ** បានដល់ការបរិនិព្វានរបស់ព្រះអរហន្ត ។

# លោកក្ដៅក្រហាយច្រឬកច្របល់ព្រោះអកុសលពិតៗ

## ១០៧. *ស្តាប់ព្រះធម៌ដើម្បីលះ*

ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងដើម្បីលះ មិនមែនដើម្បីការជាប់ជំពាក់សេចក្តីត្រូវការ ឬដើម្បីត្រូវការផលតបស្នង ។

## ១០៨. *សព្វេ ធម្មា អនត្តា*

មិនមានសត្វមិនមានបុគ្គលគឺមានតែចិត្តនិងចេតសិក ដែលកើតឡើងហើយរលត់ទៅតែប៉ុណ្ណោះ ។

## ១០៩. *ផលអទិន្នាទាន*

ក្នុងជាតិបច្ចុប្បន្ននេះបើទ្រព្យសម្បត្តិរបស់យើងវិនាសទៅត្រូវចោរលួចជាដើម គឺជាផលរបស់អទិន្នាទាន ការកាន់យករបស់អ្នកដទៃដែលគេមិនបានឲ្យក្នុងជាតិមុន ។

## ១១០. *ការខឹងក្រោធ*

សេចក្តីក្រោធកើតឡើង ប្រទូសរ៉ាយអ្នកណាត្រូវខ្លួនឯងមុនយ៉ាងពិតប្រាកដ ។

## ១១១. *សារៈនៃជីវិត*

សារៈសំខាន់នៅក្នុងជីវិត ក្នុងជាតិនេះគឺការបានស្តាប់ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ។

## ១១២. *មុននឹងស្លាប់*

យើងគ្រប់គ្នាមុខនឹងស្លាប់ចាកលោកនេះទៅយ៉ាងពិតប្រាកដ តែមុននឹងស្លាប់យើងនឹងជាមនុស្សល្អឬមនុស្សអាក្រក់ ?

# ការស្តាប់ព្រះធម៌ដើម្បីលះអវិជ្ជា

# តែស្តាប់ព្រះធម៌ហើយមិនយល់ក៏លះមិនបាន

**១១៣**. កើតគ្រប់ជាតិក៏មានត្រឹមដែលកើតឡើង ហើយក៏អស់ទៅ ។

**១១៤**. ការស្លាប់បាត់បង់ជីវិតមិនមែនជារឿងធំ តែរឿងដែលធំគឺស្លាប់គុណធម៌សេចក្ដីល្អ

**១១៥**. ស្ដាប់ព្រះធម៌រឿងមេត្តា ហើយក៏មានមេត្តា មេត្តាកើតពេលណា មេត្តាជាព្រហ្មវិហារ ជាម្លប់ដ៏ត្រជាក់របស់ចិត្ត ។

**១១៦**. ចំណងក្នុងលោកនេះឯងបាននាំជីវិតទៅរកបញ្ហារាប់មិនអស់រវល់ដោះស្រាយបញ្ហាដែលលោភៈខ្លួនឯងសាងមិនចេះចប់មិនចេះហើយ ។

**១១៧**. បញ្ចក្ខន្ធជាភារៈធ្ងន់ គឺជាទុក្ខផងការមិនប្រកាន់នូវបញ្ចក្ខន្ធគឺជាការអស់ទៅនូវទុក្ខ ព្រះនិព្វានគឺជាបរមសុខ ។

## ១១៨. *ឈ្មោះថាអ្នកមាន*

មានឬក្រគឺមាននៅក្នុងចិត្តកុំមើលទៅលើទ្រព្យសម្បត្តិ លុយកាក់ មាសប្រាក់ ទោះជាមានមាសប្រាក់ច្រើនប៉ុណ្ណា បើចិត្តនៅតែស្រេកឃ្លានក៏ឈ្មោះថានៅក្ររហេមរហាម បើចេះល្មមក្នុងចិត្តពេលណាក៏ដោយគឺជាអ្នកមានពិតប្រាកដ ។

**១១៩**. ចម្រើនមេត្តាចិត្តត្រូវគិតថាអ្នកណាៗក៏ចង់បានសុខដូចយើងដែរ ។

**១២០**. ពេលខឹងក្រោធតែងតែគិតថាខ្លួនឯងគ្រាន់បើតែតាមពិតគឺអន់សោះ ។

## ១២១. *រៀនរស់ជាមួយការពិតនៃជីវិត*

អ្វីដែលកើតរមែងកើត អ្វីដែលមានរមែងមាន រៀនរស់ជាមួយការពិតនៃជីវិត សិក្សាធម្មជាតិ អ្វីៗក្នុងលោកតែតែអស់ទៅ សូន្យទៅ សុខចិត្តព្រមជាមួយការពិតក្នុងជីវិតរបស់ខ្លួន ។

**១២២**. ខន្ធទាំងឡាយបែកធ្លាយទើបមានពាក្យថាស្លាប់ មិនមានអ្នកណាផ្សេងបែកធ្លាយក្រៅពីខន្ធទេ ។

**១២៣**. រូបជាធាតុមិនដឹងដូចជាសាកសព ចិត្តទេដែលជាអ្នកដឹងអារម្មណ៍ ចិត្តដឹងអារម្មណ៍ហើយក៏រលត់បាត់ទៅ ។

**១២៤**. *ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា* បុគ្គលដែលឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលជារបស់មិនទៀង ថាមិនទៀង ការឃើញរបស់បុគ្គលនោះជាសម្មាទិដ្ឋិ ។

**១២៥**. *ជីវិតដែលពិតប្រាកដ* កើតរលត់ៗ តៗគ្នានៃនាមនិងរូបមិនមានអ្វីដែលគួរឲ្យហួងហែងឡើយ ។

**១២៦**. *បញ្ញាដែលចូលដល់សច្ចៈធម៌* រមែងកម្ចាត់នូវភាពងងឹតក្នុងជីវិតបានដល់នូវសន្តិភាពក្នុងចិត្ត មិនបៀតបៀនអ្នកដទៃនិងខ្លួនឯង ។

# ជីវិតដែលរស់នៅដោយបញ្ញាគឺជាជីវិតដ៏ប្រសើរ

# ព្រោះបញ្ញាដោះស្រាយនូវបញ្ហា

## ១២៧. *អត់ធន់ដោះស្រាយបញ្ហា*

លោកនេះមិនមែនសុទ្ធតែល្អសព្វគ្រប់នោះទេ អ្នកមានបញ្ញាដឹងថាលោកនេះគឺបែបហ្នឹងហើយ ហើយមានសេចក្តីអត់ធន់ដោះស្រាយបញ្ហា បញ្ញាចូលទៅដឹងការពិតនៃជីវិត ការពិតនៃធម្មជាតិមិននាំឲ្យជីវិតជួបប្រទះនូវរឿងដែលកើតទុក្ខ ។

**១២៨**. *បញ្ញាដឹងហេតុនៃសេចក្តីវិនាស* ដឹងហេតុនៃសេចក្តីចម្រើន ហើយតម្កល់ជីវិតឲ្យនៅក្នុងសេចក្តីសុខចម្រើន ។

## ១២៩. *ជ័យជំនះដ៏ប្រសើរ*

ការឈ្នះចិត្តអាក្រក់របស់ខ្លួនឈ្នះកិលេសក្នុងចិត្ត ហាមចិត្តមិនឲ្យសេពគប់នូវអកុសលធម៌ អប់រំចិត្តឲ្យមានសីល មានបញ្ញា មានភាពភ្លឺស្វាង នេះឯងគឺជាជ័យជំនះដ៏ប្រសើរ ។

**១៣០.** ***ការខឹងក្រោធធ្វើឲ្យចិត្ត*** កករល្អក់ក្តៅក្រហាយ ដើរមិនសុខដេកមិនសុខ នេះគឺជាភ្លើងកើតឡើងពីខាងក្នុងចិត្តរបស់យើង ។

# ព្រះសម្មាសម្ពុទ្ធទូន្មានយើងឱ្យលះព្យាបាទដោយមេត្តា

## ១៣១. មហាចោរកំណាចទាំង៣

សត្វលោកគ្រប់គ្នាត្រូវជរាគ្របសង្កត់ ត្រូវបាត់បង់វ័យក្មេង យើងគួរពិចារណាថា ជរានេះគឺជាចោរកំណាចប្លន់យកវ័យរបស់យើងគ្រប់គ្នា ។

សត្វលោកត្រូវព្យាធិ រួបរឹតត្រូវបាត់បង់នូវសុខភាពគួរឃើញថាព្យាធិនេះគឺជាចោរកំណាចប្លន់យកនូវសុខភាពរបស់សត្វលោក ។

សត្វលោកត្រូវមច្ចុកម្ចាត់ កាលដែលមច្ចុកម្ចាត់ហើយ សត្វលោកត្រូវបាត់បង់នូវជីវិត ត្រូវគិតពិចារណាថា មច្ចុគឺជាចោរកំណាចប្លន់ជីវិតប្លន់យកអ្វីៗគ្រប់យ៉ាងក្នុងលោកទាំងអស់ ។

**១៣២**. សត្វទាំងឡាយដែលបានដល់នូវសេចក្ដីទុក្ខកន្លងទៅហើយក្ដីសេចក្ដីទុក្ខក្នុងបច្ចុប្បន្នក្ដី ឬត្រូវទទួលទុក្ខក្នុងកាលខាងមុខក្ដីព្រោះតែកិលេស បើមិនឃើញទោសកិលេសអកុសល សត្វទាំងឡាយតែងធ្លាក់ចុះក្នុងអន្លង់គឺសេចក្ដីទុក្ខ ។

**១៣៣**. រូបនេះជាសភាវចាស់គ្រាំគ្រា រូបជាសម្បុកនៃរោគ ការកើតឡើងនៃរូបគឺជាការកើតឡើងនូរោគទាំងឡាយ ការប្រាកដនៃរូប គឺជាការប្រាកដនូវ ជរានិងមរណៈនេះឯង ។

**១៣៤**. បុគ្គលអ្នកមានបបញ្ញាពិចារណានូវរូបខ្លួនឯង ថាជាធាតុមិនដឹងដូចជាសាកសព ។

**១៣៥**. ជីវិតជាទុក្ខព្រោះប្រកបដោយឧបាទានក្ខន្ធ ៥

**១៣៦**. ខន្ធ ៥ ជាទុក្ខព្រោះយើងកើតមកទើបយើង មានទុក្ខព្រោះខន្ធ ៥ កើតឡើងទើបមានទុក្ខ ទុក្ខរមែងមិន មានកាលណាដែលអស់បញ្ចក្ខន្ធ ។

**១៣៧**. ការករកើតនៃសត្វទាំង ៤ ប្រភេទ គឺកើតក្នុង ស៊ុតកើតក្នុងគភ៌ កើតក្នុងទឹក ឬទីកន្លែងដែលស្អុយរលួយ និងឧបបាតិកកំណើត ធំ ស្រេចតែម្តង កំណើតទាំងអស់នេះ ស្ថិតនៅក្នុងអំណាចមច្ចុទាំងអស់ ។

**១៣៨**. ខន្ធទាំងឡាយបែកធ្លាយទើបមានពាក្យហៅថាស្លាប់មិនមានអ្នកណាស្លាប់ផ្សេងពីខន្ធដែលបែកធ្លាយទៀតទេ ។

**១៣៩**. បើសោកសៅ មនុស្សដែលស្លាប់ទៅហើយ គួរតែសោកសៅដល់ខ្លួនឯង ដែលធ្លាក់នៅក្នុងអំណាចមច្ចុគ្រប់ពេលវេលា ព្រោះខ្លួនឯងក៏ត្រូវស្លាប់ដែរ ។

**១៤០**. មនុស្សយើងគ្រប់គ្នា មិនមានឥស្សរភាពព្រោះបញ្ចក្ខន្ធ ព្រោះកិលេស ព្រោះកម្ម សត្វលោករមែងជាប់ចំណង ។

**១៤១**. បញ្ចក្ខន្ធ ជាភារៈដ៏ធ្ងន់ចងសត្វលោកឲ្យជាប់នឹងការងារចិញ្ចឹមជីវិត ជាប់នឹងទ្រព្យសម្បត្តិ មិនឲ្យមានសេរីភាព រវល់ថែរក្សា ប៉ុន្តែបញ្ចក្ខន្ធវាសែនអកតញ្ញូ ប្រគល់ ជរា ព្យាធិ មរណៈ ដល់យើងដូច្នេះត្រូវរត់ចេញពីវា ។

**១៤២**. កិលេស អវិជ្ជា តណ្ហា ឧបាទាន មានះ ទិដ្ឋិ ជាដើមចង សត្វលោកឲ្យជាប់ នឹងការ ចាស់ ឈឺស្លាប់ ក្នុងសង្សារវដ្ត ជាប់នឹងទុក្ខលំបាកសព្វបែបយ៉ាង ។

**១៤៣**. មនុស្សយើងដែលនៅមានកិលេស រមែងជាប់នៅក្នុងគុកគឺភពតូចភពធំ ក្នុងស្រុកជនបទចេញពីភពមួយទៅភពមួយ ។

**១៤៤**. ភាជនៈដីដែលស្មូនឆ្នាំធ្វើហើយមានការបែកធ្លាយជាទីបំផុតយ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយដែលជាងគឺកម្មបានសាងមកហើយ រមែងបែកធ្លាយយ៉ាងនោះដែរ ដូច្នេះទើបមិនគួរប្រមាទ ។

**១៤៥**. មិនគួរខ្លាចកិលេស ជាងខ្លាចអ្វីៗទាំងអស់ក្នុងលោកព្រោះកិលេសនាំឲ្យយើងមានជរាមរណៈ កម្ចាត់បង់កិលេសទើបចេញពីជរានិងមរណៈបាន ។

**១៤៦**. ការប្រកាន់ហួងហែងបញ្ចក្ខន្ធ ធ្វើជាខ្លួនឯងម្ល៉ោះហើយត្រូវរវល់ចិញ្ចឹមមើលថែរក្សារការពារហួងហែងនិងរវល់ស្វែងរកអ្វីៗសព្វគ្រប់ដើម្បីផ្គាប់ផ្គុន ទាំងបញ្ចក្ខន្ធជាអ្នកសម្លាប់យើង ។

**១៤៧**. មានប្រាក់ច្រើនប៉ុណ្ណាក៏ដោយ ក៏មិនអាចគេចផុតពីសេចក្ដីស្លាប់បានឡើយ មានតែព្រះធម៌ទើបនាំឲ្យយើងផុតពីសេចក្ដីស្លាប់បាន ។

**១៤៨**. ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ជាសញ្ញាប្រាប់ឲ្យដឹងថាសេចក្ដីស្លាប់ចូលមកកាន់តែជិតហើយ។ ថ្ងៃនោះគឺជាថ្ងៃសូន្យអស់រលីងដេកម្នាក់ឯងឥតគូរ អត់ញាតិមិត្តកន្លែងដេករឹង ចង្អៀតណែន ។

**១៤៩**. អ្នកយំរកបុគ្គលអ្នកស្លាប់ទៅហើយ ជាមួយនឹងអ្នកយំប្រាថ្នាចង់បានដួងច័ន្ទ និងដួងព្រះអាទិត្យ អ្នកទាំងពីរនាក់នេះអ្នកណាល្ងង់ជាងអ្នកណា ?

**១៥០**. បញ្ចក្ខន្ធក្តី មហាភូតរូបក្តី អាយតនៈក្តី ធាតុក្តី កាមគុណក្តីប្រៀបដូចជាអសិរពិស បុគ្គលអ្នកមានប្រាជ្ញា ខំប្រឹងរត់ចេញ ដោយការប្រព្រឹត្តព្រហ្មចរិយៈ ។

**១៥១**. **ពិចារណាជីវិត** (សៀវភៅអស្តង្គតនៃជីវិត ទំព័រ ១៦០)

**១. អនិច្ចតោ** មិនទៀង

**២. ទុក្ខតោ** ជាទុក្ខព្រោះមានការកើតឡើងហើយវិនាសទៅវិញ ទុក្ខក្នុងទីនេះមិនមែនទុក្ខវេទនា ទុក្ខលក្ខណៈរួម ទុក្ខលក្ខណៈរួមទាំងទុក្ខអរិយសច្ច ព្រោះជាទីតាំងនៃទុក្ខ ។

**៣. រោគតោ** ជារោគ សង្ខារធម៌ប្រព្រឹត្តតាមអំណាចបច្ច័យ កាលណាបើវាប្រព្រឹត្តទៅតាមអំណាចបច្ច័យក៏ក្នុងអត្ថន័យជារោគដែរ ម្យ៉ាងទៀតជាទឫសគល់នៃរោគ កើតមកតាំងពីក្នុងផ្ទៃនៃមាតា ទារកតូចកើតមកជាកូនង៉ែត

ឃើញថាគួរឲ្យសង្វេគព្រោះទទួលនូវភារៈដ៏ធ្ងន់ធ្ងគឺឧបាទាន ក្ខន្ធ ទទួលរោគ ទទួលជម្ងឺ មកជាប់នឹងខ្លួនជាមួយខ្លះស្វិតដៃ ស្វិតជើង ខ្លះក៏មានជម្ងឺរឹងរៃមិនមែនមានរោគតែមួយមុខទេ នឹងឯងជាភារៈ ។

**៤. គណ្ឌតោ** ជាបូស ព្រោះប្រកបដោយរោគចាក់ដោតជាទុក្ខព្រោះមានការហូរចេញរបស់មិនស្អាតគឺ កិលេស មានការប៉ោងឡើងហើយបែកធ្លាយ ដូចជាមនុស្ស យើងកើតមកពេញវ័យហើយទ្រុឌទ្រោម ។

**៥. សល្លតោ** ជាសរ ព្រោះចាក់ដោតខាងក្នុង ព្រោះភាវៈ សព្វថ្ងៃគេប្រើសាស្ត្រាវុធកាំភ្លើង កាំបិត កាំជ្រួច ទោះជាយ៉ាងណាមិនដូចឧបាទានក្ខន្ធ នាមកនូវទុក្ខ មិនងាយនាំចេញបានកើតមកមានបញ្ចក្ខន្ធ គឺដូចជាព្រួញមុតចាក់ដោត ។

**៦. អឃតោ** ជាសេចក្តីលំបាក ព្រោះភារៈគួរឲ្យតិះដៀល មិនបាននាំមកនូវសេចក្តីចម្រើន ព្រោះជាទីតាំងនៃសេចក្តីអាក្រក់ផ្សេងៗ លំបាកព្រោះកូន លំបាកព្រោះកិច្ចការងារចិញ្ចឹមជីវិត ប៉ុន្តែមិនលំបាកដូចបញ្ចក្ខន្ធ ។

**៧. អាពាធតោ** ជាអាពាធ ព្រោះមិនឲ្យមាននូវសេរីភាព មិនដើម្បីសុខសាន្តទៅបាន ត្រូវបៀតបៀនផ្លាស់ប្តូរប្រែប្រួល ដូចជា ផស្សៈ ជាបទដ្ឋាននៃអាពាធជម្ងឺតម្កាត់ ។

**៨. បរតោ** ជារបស់ទ្រុឌទ្រោម ព្រោះទ្រុឌទ្រោមដោយ ជរា និង មរណៈ ។

**៩. ព្លិតិតោ** ជារបស់ចង្រៃ យើងមិនដែលបានឃើញបញ្ចក្ខន្ធជារបស់ចង្រៃ ព្រោះនាំមកឲ្យវិនាសមិនមែនតិចបញ្ចក្ខន្ធ ជារបស់ចង្រៃ គួរឲ្យនឿយណាយគួរឲ្យធុញទ្រាន់

មិនគួរឲ្យប្រកាន់ មិនគួរឲ្យជាប់ជំពាក់ គួរតែរើខ្លួនឲ្យផុតស្រឡះ ។

**១០. ឧបទ្ទវតោ** ជារបស់ឧបទ្រព ព្រោះនាំមកនូវសេចក្ដីក្ដៅក្រហាយច្រើន មិនអាចយើងដឹងមុនបានទេ ព្រោះជាទីតាំងនៃអន្តរាយ នាំមកនូវសេចក្ដីក្រៅក្រហាយផ្សេងៗ នាំមកនូវសេចក្ដីចង្អៀតចង្អល់ គួរតែឲ្យផុតស្រឡះតាមផ្លូវចិត្តព្រោះមិនប្រកាន់មាំ ។

**១១. ភយតោ** ជារបស់មានភ័យ ព្រោះជាអណ្ដូរកើតនៃភ័យសព្វគ្រប់ទាំងអស់ ព្រោះបដិក្ខនៃសេចក្ដីសុខស្ងប់ ជាកន្លែងភ័យផ្ទុយពីរបស់ក្សេមក្សាន្ត យើងខ្លាចកន្លែងមានភ័យបញ្ចក្ខន្ធជារបស់មានភ័យ មិនគួរសម្ងំនៅនោះទេ គួរត់ចេញដោយវិបស្សនាញាណ ។

**១២. ឧបសគ្គតោ** ជារបស់មានឧបសគ្គ ព្រោះទាក់ទង សេចក្តីក្តៅក្រហាយច្រើន ព្រោះជាទីតាំងនៃទុក្ខ ជាគ្រឿង រារាំង ។

**១៣. ចលតោ** ជារបស់ញាប់ញ័រ ញាប់ញ័រដោយជរា ព្យាធិមរណៈ ដោយលោកធម៌ ។

**១៤. បភង្គុតោ** ជារបស់ពុកផុយរលួយ ព្រោះដល់នូវ ការបែកធ្លាយជាធម្មតា ។

**១៥. អធុវតោ** ជារបស់មិនយឺនយូរ ។

**១៦. អតាណតោ** ជារបស់មិនមានទីពឹង ព្រោះមិនបាន រួចអំពីភ័យ ។

**១៧. អលេណតោ** ជារបស់មិនមានទីជ្រកពួន ទៅទី កន្លែង ណាក៏ជរាព្យាធិរកឃើញ ភ័យវិបត្តិគ្រប់យ៉ាង យើង

គេចចេញដោយការមិនប្រកាន់ហួងហែង ។

**១៨. អសរណតោ** ជារបស់មិនមានទីរលឹក ព្រោះមិនអាចជាំទីពឹងឲ្យផុតពីភ័យទុក្ខកង្វល់ ។

**១៩. រិត្តតោ** ជារបស់ទទេ មិនមានបិតស្តែឥតមានខ្លឹមសូន្យចាកភាពស្អាត សូនយចាកភាពសុខ ។

**២០. តុច្ឆតោ** ជារបស់រលីងធេង យើងពិចារណាមួយជាតិៗទទេ ផុតពីកំណើតមនុស្ស កំណើតសត្វតិរច្ឆាន ។

**២១. សុញ្ញតោ** ជារបស់សោះសូន្យ អត់មានម្ចាស់ ។

**២២. អនត្តតោ** ជារបស់មិនមែនខ្លួន ។

**២៣. អាទីនវតោ** ជារបស់មានទោស ជាប់ទៅដោយទារុណកម្ម ជាប់ដោយបញ្ហា អត់មានឥស្សរះ អត់មានសេរី

**២៤. វិបរិណាមធម្មតោ** ជារបស់ប្រែប្រួលជាធម្មតា ប្រែប្រួលដោយជរាព្យាធិមរណៈ ។

**២៥. អសារកតោ** ជារបស់ឥតខ្លឹម ព្រោះទម្លាយសេចក្ដីសុខ ។

**២៦. អឃមូលតោ** ជាឫសនៃសេចក្ដីលំបាក ។

**២៧. វធកតោ** ជាអ្នកសម្លាប់ មច្ចុតាមមករហូតតាំងពីបដិសន្ធិមក បណ្ដើរយើងទៅកន្លែងសម្លាប់ ។

**២៨. វិភវតោ** មិនមានសេចក្ដីចម្រើន ។

**២៩. សាសវតោ** ប្រកបដោយអាសវៈ ។

**៣០. សង្ខតតោ** ប្រកបដោយតាក់តែង ។

**៣១. មារាមិសតោ** ជានុយរបស់មារ ។

**៣២. ជាតិធម្មតោ** មានជាតិជាធម្មតា ។

**៣៣. ជរាធម្មតោ** មាជរាជាធម្មតា ។

**៣៤. ព្យាធិធម្មតោ** មានជរាជាធម្មតា ។

**៣៥. មរណធម្មតោ** មានសេចក្តីស្លាប់ជាធម្មតា ។

**៣៦. សោកបរិទេវ ទុក្ខទោមនស្សុបាយាសធម្មតោ** មានសោកបរិទេវទុក្ខទោមនស្ស និង ឧបាយាស្ស ជាធម្មតា ។

**៣៧. សង្កិលេសិកធម្មតោ** ប្រកបដោយគ្រឿងសៅហ្មងជាធម្មតា ។

**៣៨. សមុទយតោ** ជារបស់កើតឡើងពីហេតុ ។

**៣៩. អត្ថង្គមតោ** ជារបស់វិនាសទៅវិញ ។

**៤០. អស្សាទតោ** ជារបស់ផ្អែមដោយឆន្ទរាគ ។

**៤១. អាទីវនតោ** ជាទោសគួរឲ្យនឿយណាយ ។

**១៥២**. សិក្សាព្រះពុទ្ធសាសនា ត្រូវសិក្សាឲ្យលម្អិតដោយអត្ថនិងព្យញ្ជនៈ សិក្សារគម្ពីសំខាន់នៅក្នុងព្រះពុទ្ធសាសនាគឺគម្ពីរព្រះត្រៃបិដក មាន ១១០ ភាគ ព្រះវិន័យបិដកពីលេខ ១-១៣ ព្រះសុត្តន្តបិដកពីលេខ ១៤-៧៧ និងព្រះអភិធម្មបិដកពីលេខ ៧៨-១១០ ។

## ព្រះវិន័យបិដកមាន ៥ គម្ពីរ

១. មហាវិភង្គ

២. ភិក្ខុណីវិភង្គ

៣. មហាវគ្គ

៤. ចុល្លវគ្គ

៥. បរិវារៈ

# ព្រះសុត្តន្តបិដកមាន ៥ និកាយ

១. គម្ពីរទីឃនិកាយ ព្រះសូត្រវែងៗមាន ៣៤ សូត្រ ចែកចេញជា ៣ វគ្គ គឺ

សីលខន្ធវគ្គ មហាវគ្គ បដិកវគ្គ

**អដ្ឋកថាឈ្មោះសុមង្គលវិលាសិនី**

២. គម្ពីរមជ្ឈិមនិកាយ ព្រះសូត្រខ្នាតកណ្ដាលមាន ១៥២ សូត្រ ចែកចេញជា បី បណ្ណាសកៈ

មូលបណ្ណាសកៈ មាន ៥ វគ្គ មួយវគ្គមាន ១០ សូត្រ រួម ៥០ សូត្រ

មជ្ឈិមបណ្ណាសកៈ មាន ៥ វគ្គ មួយវគ្គ មាន ១០ សូត្រ រួម ៥០ សូត្រ

ឧបរិបណ្ណាសកៈ មាន ៥ វគ្គ បួនវគ្គ ដំបូង មាន មួយវគ្គ ១០ សូត្រ វគ្គទី ៥ មាន ១២ សូត្រ រួមជា ៥២ សូត្រ

## អដ្ឋកថាឈ្មោះបបញ្ចសូទនី

៣. សំយុត្តនិកាយ រួមព្រះសូត្រជាពួកៗ ចែកចេញជាវគ្គធំ មាន ៥ វគ្គ

| | |
|---|---|
| សគាថវគ្គ | មាន ១១ សំយុត្ត |
| និទានវគ្គ | មាន ៩ សំយុត្ត |
| ខន្ធវារវគ្គ | មាន ១៣ សំយុត្ត |
| សាឡាយតនវគ្គ | មាន ១០ សំយុត្ត |
| មហាវគ្គ | មាន ១២ សំយុត្ត |

## អដ្ឋកថាឈ្មោះសារត្ថបកាសិនី

៤. គម្ពីរអំគុត្តនិកាយព្រះសូត្រ រួមចំណែកព្រះសូត្រប្រភេទរបស់ធម៌ ចែកចេញជា ១១ និបាត

| | |
|---|---|
| ឯកនិបាត | រួមធម៌ពួក ១ |
| ទុកនិបាត | រួមធម៌ពួក ២ |
| តិកនិបាត | រួមធម៌ពួក ៣ |
| ចតុកនិបាត | រួមធម៌ពួក ៤ |
| បញ្ចកនិបាត | រួមធម៌ពួក ៥ |
| ឆកនិបាត | រួមធម៌ពួក ៦ |
| សត្តកនិបាត | រួមធម៌ពួក ៧ |
| អដ្ឋកនិបាត | រួមធម៌ពួក ៨ |
| នវកនិបាត | រួមធម៌ពួក ៩ |

ទសកនិបាត រួមធម៌ពួក ១០

ឯកទសកនិបាត រួមធម៌ពួក ១១

**អដ្ឋកថាឈ្មោះមនោរថបូរណី**

៥. ខុទ្ទកនិកាយ ក្រៅពីនិកាយបួនមានទីឃនិកាយជាដើម ព្រះពុទ្ធវចនៈ ជាដើម ព្រះពុទ្ធវចនៈដទៃរួមជានិកាយមាន

ខុទ្ទកបាឋ ធម្មបទ ឧទាន ឥតិវុត្តក សុត្តនិបាត

វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា

ជាតក មហានិទេស ចូឡនិទេស បដិសម្ភិទាមគ្គ

អបទាន ពុទ្ធវង្ស ចរិយាបិដក

**អភិធម្មមាន ៧ គម្ពីរ ភាគ ៧៧-១១០**

ធម្មសង្គនីបករណ៍ វិភង្គបករណ៍

ធាតុកថាបករណ៍ បុគ្គលប្បញ្ញត្តិ

កថាវត្ថុ យមក មហាបដ្ឋាន

ព្រះអដ្ឋកថាវិន័យបិដកមានពីរសម័យគឺអដ្ឋកថាវិន័យបិដកភាសាសីហសម័យបុរាណ ច្បាប់ដើមអន្តរធានទៅ ហើយនិងអដ្ឋកថាភាសាបាលីដែលព្រះពុទ្ធឃោសាចារ្យនិងព្រះអដ្ឋកថាចារ្យដទៃៗទៀត

**ព្រះអដ្ឋកថាភាសាសីហលសម័យបុរាណមាន ៦ គម្ពីរគឺ**

**១. មហាអដ្ឋកថា** ឬ **មូលអដ្ឋកថា** អដ្ឋកថានេះជារបស់ព្រះសង្ឃមហាវិហារក្រុងអនុរាធបុរៈប្រទេសស្រីលង្កា

**២. មហាបច្ចរីអដ្ឋកថា** រចនានៅប្រទេសស្រីលង្កា

**៣. កុរុន្ទីអដ្ឋកថា** អដ្ឋកថាភាសាអន្ទកៈ អដ្ឋកថាដែលតែងនៅកុរុន្ទីវេឡុវិហារ ប្រទេសស្រីលង្កា

៤. **អន្ធកដ្ឋកថា** អដ្ឋកថាភាសាអន្ធកៈនៅក្រុងកញ្ចិបុរៈ ប្រទេសឥណ្ឌាភាគខាងត្បូង

៥. **សង្ខេបអដ្ឋកថា** អដ្ឋកថាដោយសង្ខេប សន្និដ្ឋានថាតែង នៅប្រទេសឥណ្ឌាភាគខាងត្បូង

៦. **វិនយដ្ឋកថា** អដ្ឋកថាវិន័យបិដកភាសាបាលី សម័យព្រះពុទ្ធឃោសាចារ្យ **និងព្រះអដ្ឋកថាចារ្យរួបដទៃមាន ៣ គម្ពីរគឺ**

១. **សមន្តបាសាទិកា** រចនាដោយព្រះពុទ្ធឃោសាចារ្យ តែងនៅក្នុងពុទ្ធសករាជ ៩២៧ ដល់ ៩៧៣ ក្នុងសម័យព្រះបាទសិរិនិវាសគឺព្រះចៅមហានាមដែលមានព្រះនាមដទៃព្រះចៅសិរិកូដះ ប្រើពេលវេលា១ឆ្នាំទើបតែងចប់ ដោយការអារាធនារបស់ព្រះពុទ្ធសិរីព្រសង្ឃភណ្ឌ ប្រែជាភាសាចិន ពុទ្ធសករាជ ១០៣២

**២. គម្ពីរគន្ថាភរណី** ឬមាតិកដ្ឋកថា អដ្ឋកថាបាតិមោក្ខរចនា ដោយព្រះពុទ្ធឃោសាចារ្យ ប្រទេសស្រីលង្ការ

**៣. វិនយសង្គហដ្ឋកថា** រចនាដោយព្រះសិរីបុត្តជនជាតិស្រីលង្ការ សម័យព្រះចៅប្រាកមះពាហុ

## អដ្ឋកថាព្រះសុត្តន្តបិដក

អដ្ឋកថាសុត្តន្តបិដកមាន ២ សម័យ គឺអដ្ឋកថាសុត្តន្តបិដកភាសាសីហលសម័យបុរាណច្បាប់ដើមអន្តរធានបាត់ទៅហើយ និង អដ្ឋកថាសុត្តន្តបិដកភាសាបាលីសម័យព្រះពុទ្ធឃោសាចារ្យនិងព្រះអដ្ឋកថាចារ្យដទៃៗ មាន៧គម្ពីរ

**១. មហាអដ្ឋកថា ឬមូលអដ្ឋកថា**

**២. សុត្តន្តដ្ឋកថា** **៣. អាគមដ្ឋកថា** **៤. និយដ្ឋកថា**

**៥. មជ្ឈិមដ្ឋកថា** **៦. សំយុត្តដ្ឋកថា** **៧. អង្គុត្តរដ្ឋកថា**

**អដ្ឋកថាគាសាបាលីសម័យព្រះពុទ្ធឃោសាចារ្យនិងព្រះអដ្ឋកថាចារ្យ ដទៃៗ មាន ២៨ គម្ពីរ គឺ**

**១. សុមង្គលវិលាសិនី** អដ្ឋកថាទីឃនិកាយរចនាដោយព្រះពុទ្ធឃោសាចារ្យ

**២. បបញ្ចសូទនី** អដ្ឋកថាមជ្ឈិមនិកាយរចនាដោយព្រះពុទ្ធឃោសាចារ្យ

**៣. សារត្ថទីបនី** អដ្ឋកថាសំយុត្តនិកាយរចនាដោយព្រះពុទ្ធឃោសាចារ្យ

**៤. មនោរត្ថបូរណី** អដ្ឋកថាអង្គុតរនិកាយ រចនាដោយព្រះពុទ្ធឃោសាចារ្យ

**៥. បរមត្ថជោតិកា** អដ្ឋកថាខុទ្ទកបាឋ រចនាដោយព្រះពុទ្ធឃោសាចារ្យ

**៦. ធម្មបទដ្ឋកថា** អដ្ឋកថាធម្មបទ ខុទ្ទកនិកាយ រចនា
ដោយព្រះពុទ្ធឃោសាចារ្យ

**៧. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយឧទាន រចនាដោយ
ព្រះធម្មបាល

**៨. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយឥតិវុត្តក រចនា
ដោយព្រះធម្មបាលថេរ

**៩. បរមត្ថជោតិកា** អដ្ឋកថាខុទ្ទកនិកាយសុត្តនិបាប រចនា
ដោយព្រះពុទ្ធឃោសាចារ្យ

**១០. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយវិមានវត្ថុ រចនា
ដោយព្រះធម្មបាល

**១១. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយបេតវត្ថុ រចនា
ដោយព្រះធម្មបាល

**១២. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយថេរគាថាខុទ្ទកនិកាយ រចនាដោយព្រះធម្មបាល

**១៣. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយថេរីគាថា រចនាដោយព្រះធម្មបាល

**១៤. ជាតកដ្ឋកថា** អដ្ឋកថាខុទ្ទកនិកាយជាតក រចនាដោយព្រះពុទ្ធឃោសាចារ្យ

**១៥. សទ្ធម្មជោតកា** អដ្ឋកថាមហានិទេសនិងចូឡនិទេសរចនាដោយព្រះឧបសេន

**១៦. សទ្ធម្មបកាសិនី** អដ្ឋកថាបដិសម្ភិទាមគ្គ រចនាដោយព្រះមហានាម

**១៧. វិសុទ្ធជនវិលាសិនី** អដ្ឋកថាខុទ្ទកនិកាយអបទានមិនប្រាកដឈ្មោះអ្នកតែង

**១៨. មធុរត្ថវិលាសិនី** អដ្ឋកថាខុទ្ទកនិកាយពុទ្ធវង្ស រចនាដោយព្រះពុទ្ធទត្ត

**១៩. បរមត្ថទីបនី** អដ្ឋកថាខុទ្ទកនិកាយចរិយាបិដករចនាដោយព្រះធម្មបាលថេរ

**២០. វិសុទ្ធិមគ្គបករណវិសេស ឬវិសុទ្ធិមគ្គអដ្ឋកថា**រចនាដោយព្រះពុទ្ធឃោសាចារ្យ

**២១. មង្គលត្ថទីបនី** អដ្ឋមង្គលសូត្រ រចនាដោយព្រះសិរិមង្គលាចារ្យឈៀងម៉ៃ ប្រទេសថៃ

**២២. វេសន្តរទីបនី** អដ្ឋកថាវេសន្តរជាតក រចនាដោយព្រះសិរិមង្គលាចារ្យ នៅឈៀងម៉ៃ ប្រទេសថៃ

**២៣. ញាណោទ័យ** រចនាដោយព្រះពុទ្ធឃោសាចារ្យ

**២៨. បរត្ថអដ្ឋកថា** អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប រចនាដោយព្រះពុទ្ធឃោសាចារ្យ

## អដ្ឋកថាអភិធម្មបិដក

អដ្ឋកថាព្រះអភិធម្មបិដកមាន ២ សម័យគឺ អដ្ឋកថាសម័យភាសាសីហលសម័យបុរាណ និង អដ្ឋកថាសម័យភាសាបាលីសម័យព្រះពុទ្ធឃោសាចារ្យនិងព្រះអដ្ឋកថាចារ្យរូបដទៃទៀត ព្រះអដ្ឋកថាភាសាសីហលមាន២គម្ពីរគឺ

**១. មហាអដ្ឋកថា**ឬមូលអដ្ឋកថា សម័យបុរាណ

**២. អភិធម្មដ្ឋកថា** អដ្ឋកថាព្រះអភិធម្ម

អដ្ឋកថាអភិធម្មបិដកភាសាបាលីនិងព្រះអដ្ឋកថាចារ្យរូបដទៃរចនាមាន៤គម្ពីរ

**១. អដ្ឋសាលិនី** អដ្ឋកថាធម្មសង្គណីបករណ៍ រចនាដោយព្រះពុទ្ធឃោសាចារ្យតែងនៅប្រទេសឥណ្ឌាមុនទៅប្រទេសស្រីលង្កា

**២. សម្មោហវិនោទនី** អដ្ឋកថាវិភង្គបករណ៍ រចនាដោយព្រះពុទ្ធឃោសាចារ្យ នៅប្រទេសស្រីលង្កា

**៣. បរមត្ថទីបនី** ឬបញ្ចបករណដ្ឋកថា អដ្ឋកថាបករណ៍ទាំង ៥ គឺ ធាតុកថា ១បុគ្គលបញ្ញត្តិ ២កថាវត្ថុ ៣មយក ៤មហាបដ្ឋាន៥

**៤. អភិធម្មត្ថសង្គហ** រចនាដោយព្រះអនុរុទ្ធាចារ្យ មហាថេរៈជនជាតិឥណ្ឌា តែងនៅប្រទេសស្រីលង្កា ប្រមាណមុនពុទ្ធសករាជ ២០៤៣ (គម្ពីរអភិធម្មត្ថសង្គហនេះចាស់ជាងព្រះយេស៊ូប្រមាណ ១០០ ឆ្នាំ)

## **គម្ពីរដីកា**

**បានដល់ដីកាព្រះវិន័យដីកាព្រះសូត្រ ដីការព្រះអភិធម្ម ដីកាព្រះវិន័យមាន១០គម្ពីរ**

**១. សារត្ថទីបនីដីកា** ដីកាព្រះវិន័យជាដីការពន្យល់អធិបាយគម្ពីរសមត្ថប្បាសាទិកា រចនាដោយព្រះសារីបុត្រជនជាតិស្រីលង្ការ

**២. វមតវនោទនី** ដីកាព្រះវិន័យជាដីការអធិបាយសព្ទនិងប្រយោគក្នុងសមតប្បាសាទិកា រចនាដោយព្រះមហាកសប្បនឧទុម្ពគីរី ប្រទេសស្រីលង្ការ

**៣. វជិរពុទ្ធិដីកា** ដីការព្រះវិន័យអធិបាយសព្ទនិងប្រយោគក្នុងសមត្តប្បាសាទិកា រចនាដោយព្រះវជិរពុទ្ធិ

**៤. វនយត្ថមញ្ញូសា** ដីកាបាតិមោក្ខ រចនាដោយព្រះពុទ្ធនាគ

៥. **សុមង្គលបកាសិណី** ដីកាខុទ្ទកាសិក្ខា

៦. **វិនយត្ថសារសន្ទីបនី** ដីកាវិនិឆយសង្គហ

៧. **លិនត្ថបកាសណា** ដីកាឧត្តរវិនយវិនិឆ័យ

៨. **វិនយវិមតចឆេទនី** នវដីការមូលសិក្ខា

៩. **អនុត្តតានទីបនី** ដីការបាលិមុត្តកវិនយវិនិឆយសង្គហ

១០. **វិនយាលង្ការដីកា** ដីការបាលិមុត្តកវិនយវិនិឆយស
ង្គហ រចនាដោយព្រះបិដកលង្ការរត្ថេរ ប្រទេសភូមា

## ដីកាព្រះសូត្រមាន៧គម្ពីរ

១. **លីនត្ថបកាសនា** ដីកាទីឃនិកាយរចនាដោយព្រះធម្មបាលត្ថេរ

២. **លីនត្ថបកាសនា** ដីកាមជ្ឈិមនិកាយ

៣. **លីនត្ថបកាសនា** ដីកាសំយុត្តនិកាយ

**៤. លីនត្ថបកាសនា** ដីកានិបាតជាតក

**៥. បរមត្ថមញ្ជុសា** មហាដីកាវិសុទ្ធិមគ្គ រចនាដោយព្រះធម្មបាលត្ថេរ

**៦. សង្ខេបត្ថជោតនី** ចូឡដីកាវិសុទ្ធិមគ្គ

**៧. ដីការសច្ចសង្ខេប** រចនាដោយអាចារ្យវាចិស្សរះ ប្រទេសស្រីលង្ការ

## ដីកាព្រះអភិធម្មមានចំនួន ៧ គម្ពីរគឺ

**១. លីនត្ថបកាសិនី** មូលដីការធម្មសង្គណី រចនាដោយព្រះអានន្ទាចារ្យ ប្រទេសស្រីលង្ការ

**២. លីនត្ថបកាសិនី** អនុដីការធម្មសង្គណី

**៣. លីនត្ថជោតនា** មូលដីការវិភង្គ រចនាដោយព្រះអានន្ទាចារ្យ ប្រទេសស្រីលង្ការ

**៤. លីនត្ថបកាសិនី** អនុដីការវិភង្គ

**៥. លីនត្ថជោតនា** មូលដីការធាតុកថា រចនាដោយព្រះអាន
ន្ទាចារ្យ ប្រទេសស្រីលង្កា

**៦. លីនត្ថបកាសិនី អនុដីការធាតុកថា**

**៧. លីនត្ថជោតនា** មូលដីការបុគ្គលប្បញ្ញត្តិ រចនាដោយ
ព្រះអានន្ទាចារ្យ ប្រទេសស្រីលង្កា

**៨. លីនត្ថបការសិនី** អនុដីការបុគ្គលប្បញ្ញត្តិ

**៩. លីនត្ថជោតនា** មូលដីការកថាវត្ថុ រចនាដោយព្រះអាន
ន្ទាចារ្យ ប្រទេសស្រីលង្កា

**១០. លីនត្ថបកាសិនី អនុដីការកថាវត្ថុ**

**១១. លីនត្ថជោតនា** មូលដីការយមកៈ រចនាដោយព្រះអាន
ន្ទាចារ្យ ប្រទេសស្រីលង្កា

**១២. លីនត្ថបកាសិនិ អនុដីការយមកៈ**

**១៣. លីនត្ថជោតនា** មូលដីការបដ្ឋាន រចនាដោយព្រះអាន-

ន្ទាចារ្យ ប្រទេសស្រីលង្កា

**១៤. លីនត្ថបកាសិនី** អនុដីការបដ្ឋាន

**១៥. មធុសារត្ថទីបនី** ដីការអធិប្បាយមូលដីការ រចនាដោយ

ព្រះអានន្ទត្ថេរៈ ប្រទេសភូមា

**១៦. បុរាណដីការអភិធម្មាវតា**

**១៧. អភិធម្មត្ថវិកាសិនី** ដីការអភិធម្មាវតា រចនាដោយព្រះ

សុមង្គល

**១៨. អភិធម្មត្ថវិភាវិនី** ដីការអភិធម្មត្ថសង្គហ រចនាដោយ

ព្រះសុមង្គល ឬសុមង្គលាចារ្យ ព្រះថេរជនជាតិស្រីលង្កា

**១៩. បរមត្ថមញ្ជូសារ អនុដីការអភិធម្មត្ថសង្គហ**

**២០. មណិសារមញ្ជូសារ** នវដីកាអភិធម្មត្ថសង្គហ រចនា ដោយព្រះអរិយមង្ស: ភាគខាងជើងប្រទេសភូមា

**២១. សង្ខេបវណ្ណនា** ដីកាអភិធម្មត្ថសង្គហ រចនាដោយ ព្រះជោតិបាល ឬព្រះសទ្ធម្មជោតិបាល

**២២. អភិធម្មត្ថសង្គហទីបនី** ចូឡដីកាអភិធម្មត្ថសង្គហ រចនាដោយព្រះមហាសុវណ្ណទីបៈថេរៈ ប្រទេសភូមា

**២៣. មូលមត្ថកថា** បូរាណដីកាបរមត្ថវិនិច្ឆ័យ

**២៤. ដីកាបរមត្ថវិនិច្ឆ័យ**

**២៥. ដីកាខេមបករណ៍** រចនាដោយព្រះខេមៈកៈ

**២៦. លីនត្ថបកាសនី** បូរាណដីកានាមរូបបរិច្ឆេទ

**២៧. បរមត្ថទីបនីដីកា** ជាគម្ពីរអធិប្បាយធម្មត្ថសង្គហៈ និង អភិធម្មត្ថភាវិនី ព្រះលេឌី ឬ ញាណធជៈ ប្រទេសភូមា

# គម្ពីរយោជនា

## គម្ពីរយោជនាព្រះវិន័យមាន ៣ គម្ពីរគឺ

១. យោជនាវិន័យកែសំរួវិន័យទាំង ៥ គម្ពីរ រចនាដោយព្រះញាណគតិ ថេរះខេត្តឈៀងម៉ៃ ប្រទេសថៃ

២. យោជនាខុទ្ទកសិក្ខា

៣. យោជនាវិន័យវិនិច្ឆ័យសង្គហ រចនាដោយព្រះមហារាជគ្រូ ប្រទេសភូមា

## គម្ពីរយោជនាព្រះសូត្រ

គម្ពីរយោជនាព្រះសូត្រមាន ១ គម្ពីរគឺធម្មបទត្ថកថាយោជនា ចំពោះអត្ថកថាធម្មបទ រចនាដោយព្រះសិរីមង្គលថេរះ ប្រទេសភូមា

# គម្ពីរយោជនាព្រះអភិធម្ម

មាន៩ គម្ពីរគឺ

១. **យោជនាអត្ថយោជនី** រចនាដោយព្រះញាណកិត្តិថេរៈ ឈៀងម៉ៃប្រទេសថៃ

២. **យោជនាសមោហវិនោទនី** រចនាដោយព្រះញាណកិត្តិថេរៈ

៣. **យោជនាធាតុកថា** រចនាដោយព្រះញាណកិត្តិថេរៈ

៤. **យោជនាបុគ្គលប្បញ្ញត្តិ** រចនាដោយព្រះញាណកិត្តិថេរៈ

៥. **យោជនាកថាវត្ថុ** រចនាដោយព្រះញាណកិត្តិថេរៈ

៦. **យោជនាយមកៈ** រចនាដោយព្រះញាណកិត្តិថេរៈ

៧. **យោជនាមហាបដ្ឋាន** រចនាដោយព្រះញាណកិត្តិថេរៈ

**៨. យោជនាអភិធម្មត្ថភាវនី** ឬយោជនាដីកាអភិធម្មត្ថសង្គហ-ព្រះញាណកិត្តិថេរៈ

**៩. យោជនាអភិធម្មត្ថសង្គហ**

# ចប់

## សូមរីករាយជ្រះថ្លាសិក្សាព្រះធម៌អាន

## សៀវភៅ ធម៌អប់រំចិត្តភាគ ១ ជាបន្ត

## អ្នកមានឧបការធម្មទាន

| | | |
|---|---|---|
| ភិក្ខុកល្យាណធម្មោ | **ម៉ន សាមឿន** | វត្តរាជបូរណ៍ |
| ភិក្ខុចិន្តមនោ | **ហាន នឿម** | វត្តសំពៅមាស |
| ឧបាសិកា | **រស់ ជិន** | ក្រុង ភ្នំពេញ |
| ឧបាសិកា | **ស៊ាម ផេង** | ខេត្តកំពង់ចាម |
| ឧបាសិកា | **លឹម ចន្ថន** | ខេត្តសៀមរាប |
| ឧបាសិកា | **សំណាង ស្រីពៅ** | ខេត្តកំពង់ចាម |
| ឧបាសិកា | **ឱ ដាលី** | ខេត្តកំពង់ចាម |
| ឧបាសិកា | **ឃាង សុផល** | ខេត្តកំពង់ចាម |
| ឧបាសក | **មី សុជាតិ** | ខេត្តតាកែវ |
| ឧបាសក | **អ៊ុម ប៊ុនជា** | វត្តនិគ្រោធវ័ន |
| យុវជន | **ជាម លីប៉ូ** | ក្រុងភ្នំពេញ |
| យុវជន | **គីន សុខគាង** | ក្រុងភ្នំពេញ |

**សៀវភៅ**

**ជីវិតគឺជាធម្មៈ**

**រៀបរៀង**

ភិក្ខុបញ្ញានន្ទោ **សុង គីមសាន្ត**

**សហការីកុំព្យូទ័រ**

ភិក្ខុសន្តិធម្មោ **លន់ សុឃា**

**ស្ថានទីធ្វើ**

វត្តសិរិនថនទេពរ័តនារាម មហាវិទ្យាល័យ

Mahamakut Buddhist University

**ទំនាក់ទំនង**

E-mail:sungkimsan36@gmail.com

www.facebook.com/ sungkimsan

សូមឧទ្ទិសធម្មទាននេះដល់សព្វសត្វ ទេវតា មនុស្ស អមនុស្ស សូមមានចិត្តសោមនស្សត្រេកអរជ្រះថ្លា អនុមោទនា សូមឲ្យបានដល់នូវសេចក្ដីសុខចុះ ។

សាធុ! សាធុ! សាធុ!

**អាសយដ្ឋាន** មហាវិទ្យាល័យ មហាមកុដរាជវិទ្យាល័យ
ស្រុក ពុទ្ធមណ្ឌល ខេត្តនគរបឋម ប្រទេសថៃ

Tel: (66) 0-2800-2773-4

E-mail: mrjatapat@hotmail.com


សូមរីករាយជ្រះថ្លាសិក្សាព្រះធម៌តាមអ៊ីធឺណែត
www.5000-years.org